# ឈ្នួលនៃការមើល
# រូបអាសអាភាស

THE COST OF VIEWING PORN



TIM CHALLIES | PAUL MAXWELL | ANDREW NASELLI | OWEN STRACHAN

ផ្លូវពិត
plovpit.com

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម៖ លោកគ្រូ Andrew David Naselli, លោកគ្រូ Owen Strachan, លោកគ្រូ Tim Challies និងលោកគ្រូ Paul Maxwell
បកប្រែដោយមានការអនុញ្ញាត
All rights reserved by original authors © 2017
Used by permission

ផលិតដោយ៖ សកម្មភាពកម្ពុជា resources@actioncambodia.org
បកប្រែដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់ និងលោក ទេព រ៉ូ
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក អ៊ុន ជ័យរិទ្ធ, កញ្ញា ថន ស្ថាពរ, លោក ឯក ម៉ានិល, លោក ជឿន ជីវិចន្ទា, កញ្ញា ជឿន ចាន់លាប, កញ្ញា ខឹម ផល្លី, កញ្ញា យ៉ុន សាឯម, លោកស្រី ធី លីដា, លោក ថាច់ ទិត្យសូរិយា, កញ្ញា អ៊ូ គឹមហ៊ុន, លោកស្រី ឈឿន សុផាន់ណា, និងលោកស្រី សំ ថាវី

ការប្រើប្រាស់បទព្រះគម្ពីរបរិសុទ្ធ និងជីវិសុទ្ធ និងព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤មានការអនុញ្ញាតពីសមាគមព្រះគម្ពីរកម្ពុជា និងរក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត។
មានការអនុញ្ញាតការប្រើប្រាស់បទព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ-សញ្ញាថ្មី រក្សាសិទ្ធិ © ២០១២ ព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦ (គកស), ព្រះគម្ពីរជីវិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ www.plovpit.com
បោះពុម្ពលើកទី១ ចំនួន៣០០០ក្បាល គ.ស. ២០១៧ នៅព្រះរាជាណាចក្រកម្ពុជា

# មាតិកា


១ ហេតុផល៧យ៉ាងដែលមិនគួរបណ្តោយខ្លួនទៅ
មើលរូបអាសអាភាស ........ ៥

២ លទ្ធផលនៃការមើលរូបភាពអាសអាភាស
ដែលឥតគិតថ្លៃ ........ ៣៩

៣ ការកុហក៥យ៉ាងចេញពីការមើលរូបមិនគប្បី ........ ៤៧

៤ ភាពបរិសុទ្ធបែបវិជ្ជមាន ........ ៥៩

៥ ទង្វើ៧យ៉ាងដែលយើងគួរធ្វើបន្ទាប់ពី
មើល រូបភាពមិនគប្បី ........ ៦៥

# ១ ហេតុផល៧យ៉ាងដែលមិនគួរបណ្ដោយខ្លួនទៅមើលរូបអាសអាភាស

បច្ចុប្បន្ននេះ រូបភាពអាសអាភាសពិតជាទទួលបាននូវភាពទាក់ទាញពីសំណាក់អ្នកមើលគ្រប់ស្រទាប់វណ្ណៈយ៉ាងខ្លាំង។ មិនត្រឹមតែមនុស្សពេញវ័យ ឬក៏ក្មេងជំទង់ដែលពួកគេតែងតែបណ្ដោយខ្លួនទៅមើលរូបភាពអាសអាភាសទាំងនោះទេ សូម្បីតែអ្នកដែលបានតាំងខ្លួន និងបានហៅខ្លួនឯងថា ជាគ្រីស្ទបរិស័ទ ក៏បាននាំគ្នាមើលរូបភាពទាំងអស់នោះដែរ។ នៅត្រង់ឃ្លាដែលថា៖ “បណ្ដោយខ្លួនទៅមើលរូបភាពអាសអាភាស” នេះ គឺខ្ញុំចង់សំដៅទៅលើអស់អ្នកដែលអនុញ្ញាតឲ្យខ្លួនឯងប្រព្រឹត្តនូវអំពើបាបក្នុងបំណងទទួលបានភាពអរសប្បាយតាមរយៈរូបភាព ឬវីដេអូដែលទាក់ទងនឹងរឿងអាសអាភាស ឬក៏រូបភាពអាក្រាត ក៏ដូចជាការបង្ហាញភាពលេចលើលេចក្រោម ដែលបង្កើត

ឲ្យមានអារម្មណ៍ស្រើបស្រាល និងមានតម្រេកក្នុងការរួមដំណេកជាដើម។ បញ្ហាចម្បង និងជាដើមចមនៃបញ្ហានេះគឺ បណ្តាលមកពីភាពទូលំទូលាយនៃបច្ចេកវិទ្យា ការជឿនលឿននៃប្រព័ន្ធអ៊ីនធឺណិត ដែលទាំងអស់នេះធ្វើឲ្យមានភាពងាយស្រួលក្នុងការទាញយករូបភាពអាសអាភាស ក៏ដូចជាវីដេអូដែលបង្ហាញពីការរួមភេទពីគេហទំព័រផ្សេងៗ។

ឯកសារនេះ បានរៀបចំឡើងក្នុងគោលបំណង ចង់ឲ្យលោកអ្នកចេះបដិសេធនឹងការមើលរូបភាពអាសអាភាសទាំងនោះ ដោយពឹងផ្អែកលើព្រះគុណរបស់ព្រះជាម្ចាស់ដ៏ជាព្រះវរបិតានៃយើង។ យ៉ាងណាមិញ ឯកសារនេះពុំបានបកស្រាយលម្អិតអំពីរបៀប ឬវិធីសាស្ត្រនៃការតយុទ្ធក្នុងការមើលរូបភាពអាសអាភាសនោះទេ ដោយហេតុថាមានអត្ថបទ និងឯកសារផ្សេងៗជាច្រើនទៀតដែលមានបង្ហាញពីវិធីតយុទ្ធនេះយ៉ាងលម្អិត។ គោលបំណងដ៏ពិតរបស់យើងខ្ញុំតាមរយៈឯកសារមួយនេះ គឺ*ចង់លើកទឹកចិត្ត* លោកអ្នកបងប្អូន កុំឲ្យចុះចូល ឬបណ្តោយខ្លួនទៅមើលរូបភាពអាសអាភាសទាំងនោះឡើយ។ ជាពិសេស គឺចង់លើកទឹកចិត្តដល់លោកអ្នកដែលចុះចូល ឬបណ្តោយខ្លួនទៅមើលរូបទាំងនោះម្តងហើយម្តងទៀត ក៏ដូចជាអ្នកដែលពុំបានកែប្រែចិត្ត ឬព្យាយាមកែទម្លាប់ក្នុងភាពត្រេកត្រអាលនៃកាមតណ្ហា ឬចំណង់នៃអំពើបាបរបស់ខ្លួនផងដែរ។ ជាងនេះទៅទៀត ប្រសិនបើអត្ថបទនេះបានប៉ះពាល់ចិត្តលោកអ្នក ហើយមានអារម្មណ៍ថា វាពិពណ៌នាអំពីលោកអ្នក។ ដូច្នេះឯកសារមួយនេះពិតជាជំនួយដ៏ល្អសម្រាប់លោកអ្នកមែន។ ឯកសារនេះ ប្រៀបដូចជាយើងខ្ញុំផ្ទាល់កំពុងមានវត្តមានចាំជួយ

បង្វែរ ការពារ និងចាំជួយប្រាប់អ្នកទាំងអស់គ្នាទាំងទឹកភ្នែកថា៖ «ចូរភ្ញាក់ឡើង! តើលោកអ្នកបានដឹងពីលទ្ធផលនៃការបណ្ដោយខ្លួនទៅមើលរូបភាពអាសអាភាសដែរឬទេ?»

ខាងក្រោមនេះ គឺជាហេតុផលប្រាំពីរយ៉ាងដែលយើងខ្ញុំ មានបំណងចង់លើកទឹកចិត្តដល់លោកអ្នកថា កុំឲ្យបណ្ដោយខ្លួនទៅមើលរូបភាពអាសអាភាស៖

## ១. ការបណ្ដោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាសនឹងបណ្ដាលឲ្យលោកអ្នកធ្លាក់នរក

សេចក្ដីអត្ថាធិប្បាយដ៏ល្បីល្បាញរបស់ព្រះយេស៊ូវនៅលើភ្នំ ព្រះអង្គមានបន្ទូលអំពីសេចក្ដីតម្រេកស្រើបស្រាលក្នុងកាមតណ្ហាថា៖

«អ្នករាល់គ្នាបានឮសេចក្ដី ដែលសម្ដែងពីដើមថា «កុំផិតឲ្យសោះ» ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលគ្រាន់តែក្រឡេកឃើញស្ត្រី ហើយមានតម្រេកសម្រើបចង់បាន នោះឈ្មោះថា បានប្រព្រឹត្តសេចក្ដីកំផិតនឹងនាងនោះ នៅក្នុងចិត្តខ្លួនហើយ បើភ្នែកស្ដាំអ្នកនាំឲ្យរវាតចិត្ត នោះចូរខ្វេះចេញបោះចោលទៅ ដ្បិតដែលភ្នែកអ្នក១ត្រូវវិនាស នោះមានប្រយោជន៍ ជាជាងឲ្យរូបកាយទាំងមូលត្រូវបោះទៅក្នុងនរក ហើយបើដៃស្ដាំអ្នកនាំឲ្យរវាតចិត្ត នោះចូរកាត់ចេញបោះចោលទៅ ដ្បិតដែលដៃអ្នកម្ខាងត្រូវវិនាស នោះមានប្រយោជន៍ជាជាងឲ្យរូបកាយទាំងមូល ត្រូវបោះទៅក្នុងនរក» (ម៉ាថាយ ៥:២៧-៣០)។

ព្រះអម្ចាស់បានកាត់ស្រាយនូវអត្ថន័យនៃពាក្យបម្រាមថា «កុំផិតឲ្យសោះ»

ប្រកបដោយអំណាចចេស្តា។ ទោះជាយ៉ាងណាក៏ដោយ បម្រាមនេះមិនគ្រាន់តែហាមលោកអ្នកមិនឲ្យទៅលួចប្រពន្ធអ្នកដទៃប៉ុណ្ណោះទេ តែថែម-ទាំងបានហាមលោកអ្នកកុំឲ្យមានតម្រេកស្រើបស្រាលក្នុងកាមតណ្ហាផងដែរ។ ព្រះយេស៊ូវមានបន្ទូលថា ការមើលឃើញស្ត្រីណាម្នាក់ដោយមានចិត្តចង់រួមដំណេកជាមួយគឺជា អំពើបាប។ ដូច្នេះហើយ ប្រសិនបើលោក-អ្នកបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស នោះមានន័យថាលោកអ្នកកំពុងប្រព្រឹត្តអំពើបាបហើយ។

បន្ទាប់មកព្រះអម្ចាស់បានសន្និដ្ឋានដោយសមហេតុផលថា៖ «ដោយសារការមើលស្ត្រីណាម្នាក់ ហើយមានតម្រេកចង់រួមដំណេកជាមួយនាងជាអំពើបាប *ហេតុដូច្នេះហើយ* លោកអ្នកត្រូវតែខ្វេះភ្នែកនោះចោល បើវាបណ្តាលឲ្យលោកអ្នកធ្វើបាប។ ហើយលោកអ្នកក៏គួរតែកាត់ដៃស្តាំរបស់ខ្លួនចោលដែរ ប្រសិនបើវាបណ្តាលឲ្យលោកអ្នកធ្វើបាបនោះ»។ ព្រះអម្ចាស់បានគាំ-ទ្រសេចក្តីសន្និដ្ឋានរបស់ទ្រង់ដោយមានហេតុផលយ៉ាងសមស្រប គឺដែលបាត់បង់ភ្នែក ឬក៏ប្រដាប់ភេទនោះប្រសើរជាងឲ្យរូបកាយទាំងមូលរបស់លោកអ្នកធ្លាក់ទៅក្នុងនរក។

ចំពោះមនុស្សដែលបណ្តោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាសឥតឈប់ឈរ មើលម្តងហើយម្តងទៀតដោយពុំមានការកែប្រែចិត្ត នោះនឹងត្រូវធ្លាក់នរកជាប្រាកដ។ ភស្តុតាងមួយដែលបង្ហាញថា លោកអ្នកមានជំនឿលើព្រះយេស៊ូវ គឺត្រង់ថា លោកអ្នកកំពុងតែតយុទ្ធនឹងសេចក្តីស្រើបស្រាលនោះ។ ការបណ្តោយខ្លួនទៅប្រឡូកប្រឡាក់នឹងរឿងអាសអាភាស គឺជាអំពើ

បាបដែលទាក់ទងនឹងសេចក្ដីកំផិតៈ

“ឯសេចក្ដីកំផិត សេចក្ដីស្មោកគ្រោកគ្រប់យ៉ាង និងសេចក្ដីលោភ នោះមិនត្រូវទាំងឲ្យឮឈ្មោះក្នុងពួកអ្នករាល់គ្នាផង ដូចជាគួរគប្បីក្នុងពួកបរិសុទ្ធ ព្រមទាំងរឿងគួរខ្មាស ពាក្យសំដីចំកួត និងពាក្យកំប្លែង ដែលសេចក្ដីទាំងនោះមិនគួរគប្បីដែរ ស៊ូពោលតែពាក្យសម្រាប់អរព្រះគុណវិញ ដ្បិតអ្នករាល់គ្នាដឹងថា គ្មានមនុស្សកំផិត ឬស្មោកគ្រោក ឬលោភ គឺជាមនុស្សថ្វាយបង្គំរូបព្រះ ដែលនឹងគ្រងមរតកក្នុងនគរនៃព្រះគ្រីស្ទ ហើយនៃព្រះផងបានឡើយ កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នា ដោយពាក្យសំដីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្ដីទាំងនោះ បានជាសេចក្ដីក្រោធរបស់ព្រះ បានមកលើមនុស្សរឹងចចេស” (អេភេសូរ ៥:៣-៦)។

“តើអ្នករាល់គ្នាមិនដឹងថា ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតមិនអាចគ្រងព្រះរាជ្យរបស់ព្រះទុកជាមរតកបានទេឬ? សូមកុំច្រឡំឲ្យសោះ! ពួកសហាយស្មន់ ពួកថ្វាយបង្គំរូបព្រះ ពួកផិតក្បត់ ពួកប្រុសពេស្យា ពួករួមសង្វាសនឹងភេទដូចគ្នា ពួកចោរ ពួកលោភលន់ ពួកប្រមឹក ពួកជេរប្រមាថ ពួកបោកប្រាស់ នោះមិនអាចគ្រងព្រះរាជ្យរបស់ព្រះទុកជាមរតកបានឡើយ។ ពីដើមអ្នករាល់គ្នាខ្លះក៏ធ្លាប់ជាមនុស្សបែបនោះដែរ តែព្រះបានលាងសម្អាតអ្នករាល់គ្នា បានញែកអ្នករាល់គ្នាជាបរិសុទ្ធ បានរាប់អ្នករាល់គ្នាជាសុចរិត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងដោយសារព្រះវិញ្ញាណនៃព្រះរបស់យើងរួចហើយ” (១កូរិនថូស ៦:៩-១១ គកស)។

មួយវិញទៀត អស់អ្នកដែលបានបណ្តោយខ្លួនមើលរូបភាព ឬវីដេអូអាស-

អាភាស ក៏រាប់បញ្ចូលជា «មនុស្សកំផិត» ផងដែរ។ យើងក៏អាចបកស្រាយនូវកណ្ឌគម្ពីរ ១កូរិនថូស ៦:៩-១០ ថា៖ «ចូរកុំគិតថាខ្លួនអាចរស់នៅ ហើយគេចចេញផុតពីអំពើបាបដោយគ្មានការផ្លាស់ប្រែចិត្តឡើយ និងសូមកុំគិតថាលោកអ្នកអាចបន្តរស់នៅក្នុងលក្ខណៈបែបនេះ ហើយអាចរស់នៅក្នុងនគររបស់ព្រះជាម្ចាស់បានឡើយ។ ការរស់នៅក្នុងអំពើបាប ដោយពុំមានការកែប្រែចិត្ត ពិតជាពុំស័ក្តិសម ហើយនេះមិនមែនជាលក្ខណសម្បត្តិនៃរាស្ត្ររបស់ព្រះជាម្ចាស់ឡើយ»។

ឯកណ្ឌគម្ពីរ ១កូរិនថូស ៦:១១ គឺជារាជសារក្រើនរំឭកដល់កូនរបស់ព្រះថា៖ «ពីដើម ពួកគាត់មិនមែនល្អប្រសើរជាងអ្នកដែលមិនជឿប៉ុន្មាននោះទេ។ រាល់អំពើបាបដែលអ្នកមិនជឿបានប្រព្រឹត្តក៏សុទ្ធតែជាអំពើបាបដែលអ្នកជឿធ្លាប់ប្រព្រឹត្តដែរ គឺនៅមុនពេលដែលព្រះអម្ចាស់សង្គ្រោះពួកគេ។ ជាការពិតណាស់ រាល់អ្វីៗដែលកណ្ឌគម្ពីរ ១កូរិនថូស ៦:៩-១០ បានលើកឡើង គឺជាការឆ្លុះបង្ហាញពីមនុស្សមានបាប ក៏ដូចជារៀបរាប់ពីអ្វីដែលគ្រីស្ទបរិស័ទបានប្រព្រឹត្តដែរ។ ភាពខុសគ្នាតែមួយរវាងអ្នកជឿ និងអ្នកមិនជឿនោះត្រង់ថា ព្រះអម្ចាស់បានធ្វើអន្តរាគមន៍៖ ព្រះអង្គ «បានលាង» លោកអ្នកឲ្យស្អាតពីជីវិតរស់នៅដ៏ទុច្ចរិត ហើយបានអត់ទោសបាបរបស់លោកអ្នក។ ទ្រង់ក៏ «បានញែក» លោកអ្នក «ជាបរិសុទ្ធ» ដើម្បីឲ្យលោកអ្នកធ្វើជារាស្ត្រដ៏បរិសុទ្ធរបស់ទ្រង់ដែរ ហើយរាស្ត្រនោះ គឺជាព្រះវិហាររបស់ព្រះវិញ្ញាណបរិសុទ្ធ (១កូរិនថូស ៣:១៦-១៧)។ ព្រះអម្ចាស់ក៏បានរាប់លោកអ្នកជា «សុចរិត» ដោយប្រកាសតាមផ្លូវច្បាប់ថា លោកអ្នកជាមនុស្សសុចរិត។

យ៉ាងណាមិញ ចូរកុំគិតថា វាជារឿងតូចតាចឲ្យសោះ ក្នុងការដែលលោក-អ្នកបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសនោះ។ ក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៦:៩-១០ ក៏បានបកស្រាយយ៉ាងច្បាស់ដែរថា មនុស្សមានបាបដែលបានរៀបរាប់ក្នុងកណ្ឌគម្ពីរ គឺតំណាងឲ្យប្រភេទមនុស្សដែលពុំមែនជារាស្ត្រក្នុងនគររបស់ព្រះអម្ចាស់ទេ។ ជាងនេះទៅទៀត លោកអ្នកពុំអាចហៅខ្លួនឯងថាជាគ្រីស្ទបរិស័ទបានឡើយ ប្រសិនបើលោកអ្នកនៅតែបណ្ដោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាសជាបន្តបន្ទាប់នោះ។ ការដែលគ្រីស្ទបរិ-ស័ទប្រព្រឹត្តបាប គឺជាការពិត ប៉ុន្តែគ្រីស្ទបរិស័ទគឺជាមនុស្សដែលចេះលន់តួបាប ហើយកែប្រែចិត្តគំនិត។ ដូច្នេះ ចូរលោកអ្នកទទួលយកលក្ខណៈដែលព្រះជាម្ចាស់បានប្រទានឲ្យលោកអ្នក បានលាងសម្អាត បានញែកជាបរិសុទ្ធ និងបានរាប់ជាសុចរិតចុះ។

លើសពីនេះទៅទៀត ការដែលលោកអ្នកបណ្ដោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាសនោះគឺជា អំពើបាបដែលក្បត់នឹងព្រះជាម្ចាស់ ហើយជី-វិតអស់កល្បរបស់លោកអ្នកគឺកំពុងតែប្រឈមមុខនឹងហានិភ័យ។ ហេតុដូចនេះហើយបានជាព្រះយេស៊ូវមានបន្ទូលថា៖ «មានពរហើយអស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកនោះនឹងបានឃើញព្រះ» (ម៉ាថាយ ៥:៨)។ មានតែអ្នកដែលមានចិត្តបរិសុទ្ធប៉ុណ្ណោះដែលអាចមើលឃើញព្រះជាម្ចាស់បាន។ បើលោកអ្នកនៅតែបណ្ដោយខ្លួនមើលរូបភាពអាស-អាភាស នោះមានន័យថា លោកអ្នកពុំមានចិត្តបរិសុទ្ធឡើយ។ *យើងខ្ញុំកំពុងតែបន្លាចលោកអ្នកឲ្យដកខ្លួនចេញពីស្ថាននរក។* តើលោកអ្នកជឿ

ទេថា បើលោកអ្នកគ្រាន់តែបណ្តោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាស បណ្តាលឲ្យលោកអ្នកធ្លាក់នរក?

សូមព្យាយាមធ្វើអ្វីៗទាំងអស់ ដើម្បីតយុទ្ធនឹងភាពស្រើបស្រាលក្នុងកាមតណ្ហា ទោះបីជាលោកអ្នកត្រូវខ្វេះគ្រាប់ភ្នែកចោលក៏ដោយ។ ពិតប្រាកដណាស់ ការដែលខ្វេះភ្នែករបស់ខ្លួនឯងចោលពុំអាចដោះស្រាយបញ្ហាបានទេ ព្រោះភាពស្រើបស្រាលក្នុងកាមតណ្ហា គឺជាបញ្ហាដែលបណ្តាលមកពីចិត្ត ហើយទាក់ទងនឹងការគ្រប់គ្រងចិត្ត។ គ្មានអាវុធ ឬយុទ្ធសាស្ត្រដ៏ពិតប្រាកដណាមួយដែលលោកអ្នកអាចយកមក តយុទ្ធនឹងចម្បាំងនៃកាមតណ្ហាបានឡើយ។ ដូច្នេះ លោកអ្នកត្រូវព្យាយាមប្រើគ្រប់យុទ្ធសាស្ត្រ ដើម្បីយកឈ្នះវាឲ្យបាន។ លោកអ្នកអាចប្រើកម្មវិធីអេឡិចត្រូនិក ដើម្បីរារាំងនូវកម្មវិធីដែលមានរូបភាពទាំងនោះ ឬលោកអ្នកអាច ស្វែងរកគ្រូគង្វាលរបស់ខ្លួន ដើម្បីឲ្យគាត់ជួយមើលការខុសត្រូវ ជួយកែជីវិតរបស់លោកអ្នក ហើយនិយាយដោយចំហអំពីបញ្ហារបស់លោកអ្នកទៅគាត់។ សូមលោកអ្នកប្រាប់ខ្លួនឯងឲ្យជៀសឆ្ងាយអំពីគេហទំព័រដែលនាំឲ្យលោកអ្នកប្រព្រឹត្តការខុសឆ្គង ហើយសូមប្រើរាល់វិធីសាស្ត្រដែលលោកអ្នកអាចនឹងយកជ័យជម្នះដើម្បីឲ្យលោកអ្នកយកឈ្នះសង្គ្រាមនៃភាពស្រើបស្រាលនេះ ហើយជ័យជម្នះនេះពិតជាមានតម្លៃណាស់ ពីព្រោះលោកអ្នកអាចជៀសផុតពីអំពើបាប និងស្ថាននរក។

## ២. ការបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស មិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់ក្នុងរូបកាយរបស់លោក-អ្នកឡើយ

ការថ្វាយសិរីល្អដល់ព្រះ គឺជាអារម្មណ៍ ជាគំនិត និងជាការប្រព្រឹត្តមួយបែប របស់យើង ក្នុងការបង្ហាញថា ព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់។ ជាងនេះទៅទៀត ការថ្វាយសិរីល្អដល់ព្រះអង្គ គឺជាការដែលយើងបង្ហាញថា ទ្រង់ឧត្តុង្គ-ឧត្តម មានភាពល្អឥតខ្ចោះ និងសប្បុរសបំផុត។ ការនេះក៏ជាការ បង្ហាញថា ព្រះជាម្ចាស់ប្រកបដោយប្រាជ្ញា ហើយមានតែទ្រង់មួយព្រះអង្គប៉ុណ្ណោះ ដែលអាចធ្វើឲ្យយើងស្កប់ចិត្តបាន។ នៅពេលដែលយើងកាន់តែស្កប់ចិត្តនឹងព្រះជាម្ចាស់ នោះទ្រង់នឹងកាន់តែទទួលសិរីល្អពីយើង។ នេះហើយជាហេតុផល ដែលព្រះជាម្ចាស់បានបង្កើតយើងមក។ ការដែលលោកអ្នកប្រើភ្នែករបស់ខ្លួន ទៅមើលរូបភាព ឬវីដេអូអាសអាភាស ការនេះមិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈរូបកាយរបស់លោកអ្នកឡើយ។

“អ្នកខ្លះពោលថា “ខ្ញុំមានច្បាប់នឹងធ្វើការទាំងអស់បាន” ប៉ុន្តែ មិនមែនការទាំងអស់សុទ្ធតែមានប្រយោជន៍នោះទេ។ “ខ្ញុំមានច្បាប់នឹងធ្វើការទាំងអស់បាន” ប៉ុន្តែ ខ្ញុំមិនឲ្យអ្វីមួយធ្វើចៅហ្វាយលើខ្ញុំឡើយ។ អ្នកខ្លះទៀតពោលថា “អាហារសម្រាប់ចម្អែតក្រពះ ហើយក្រពះសម្រាប់ទទួលអាហារ” តែព្រះនឹងបំ-ផ្លាញទាំងពីរនេះចោល។ រូបកាយមិនមែនសម្រាប់ប្រព្រឹត្តអំពើសាហាយស្មន់ទេ គឺសម្រាប់ព្រះអម្ចាស់វិញ ហើយព្រះអម្ចាស់ក៏សម្រាប់រូបកាយដែរ។ ព្រះដែលបានប្រោសព្រះអម្ចាស់ឲ្យរស់ឡើងវិញ ទ្រង់ក៏នឹងប្រោសយើងឲ្យរស់

ឡើងវិញ ដោយសារព្រះចេស្តារបស់ព្រះអង្គដែរ។ តើអ្នករាល់គ្នាមិនដឹងថា រូបកាយរបស់អ្នករាល់គ្នាជាអវយវៈរបស់ព្រះគ្រីស្ទទេឬ? ដូច្នេះ តើគប្បីឲ្យខ្ញុំយកអវយវៈរបស់ព្រះគ្រីស្ទ ទៅធ្វើជាអវយវៈរបស់ស្ត្រីពេស្យាឬ? ទេ មិនបានជាដាច់ខាត! តើអ្នករាល់គ្នាមិនដឹងថា អ្នកណាដែលរួមរ័កជាមួយស្ត្រីពេស្យា អ្នកនោះជារូបកាយតែមួយជាមួយនាងទេឬ? ដ្បិតមានសេចក្តីចែងទុកមកថា «អ្នកទាំងពីរនឹងត្រឡប់ជាសាច់តែមួយ» រីឯអ្នកដែលរួមរស់ជាមួយព្រះអម្ចាស់វិញ នោះក៏ជាវិញ្ញាណតែមួយជាមួយព្រះអង្គដែរ។ ចូររត់ចេញពីអំពើសាហាយស្មន់ទៅ! រាល់អំពើបាបដែលមនុស្សប្រព្រឹត្ត នោះនៅខាងក្រៅរូប-កាយទេ តែអ្នកដែលប្រព្រឹត្តសាហាយស្មន់ អ្នកនោះធ្វើបាបទាស់នឹងរូបកាយរបស់ខ្លួនហើយ។ តើអ្នករាល់គ្នាមិនដឹងថា រូបកាយរបស់អ្នករាល់គ្នាដែលអ្នករាល់គ្នាបានទទួលមកពីព្រះទេឬ? អ្នករាល់គ្នាមិនមែនជារបស់ខ្លួនឯងទៀតទេ ដ្បិតព្រះបានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរលើកតម្កើងព្រះ នៅក្នុងរូបកាយរបស់អ្នករាល់គ្នាចុះ» (១កូរិនថូស ៦:១២-២០ គកស)។

នៅក្នុងអត្ថបទនេះ សាវ័ក ប៉ុល បានលើកឡើងអំពីបញ្ហាមួយទៀតដែលមាននៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស នៅត្រង់ចំណុចមួយដែលក្រុមជំនុំកូរិនថូសបានទទួលយកទស្សនៈរបស់លោកីយ៍ ព្រមទាំងវប្បធម៌របស់ពួកអ្នកថ្វាយបង្គំព្រះក្លែងក្លាយ៖ ដោយយកលេសទៅប្រព្រឹត្តអំពើកំផិត។ ក្រឡេកមើលទៅពួកមនុស្សប្រុសដែលនៅក្រុងកូរិនថូស ដែលបានអះអាងខ្លួនជាគ្រីស្ទបរិស័ទវិញ ក៏ទំនងជាបានរួមភេទជាមួយស្ត្រីពេស្យា ក្រោយពេលបញ្ចប់ពិធីជប់លៀងរួច។ ត្រង់ចំណុចនេះយើងឃើញថា សាវ័ក ប៉ុល កំពុងតែសរសេរប្រឆាំងនឹងការ

កំផិតមួយប្រភេទ (ការរួមភេទជាមួយស្ត្រីពេស្យា) ទោះបើអ្វីដែលគាត់បាន លើកឡើងនោះក៏បានផ្តោតទៅលើការរួមភេទក្រៅរង្វង់អាពាហ៍ពិពាហ៍របស់ ខ្លួន រួមទាំងការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសដែលការ នោះក៏ជាការកំផិតមួយប្រភេទផងដែរ។

នៅត្រង់ ខ១៩ ដល់ ២០ បានគាំទ្រ ខ១៨គ និងបានពន្យល់មូលហេតុ ដែលថា ការរួមដំណេកក្រៅរង្វង់អាពាហ៍ពិពាហ៍ គឺជាការធ្វើបាបដែលទាស់ នឹងរូបកាយរបស់ខ្លួនអ្នក។ យើងអាចសម្រាយ ខ១៩ ដល់ ២០ក បានដូច តទៅ៖ ឱគ្រីស្ទបរិស័ទអើយ! រូបកាយរបស់លោកអ្នកគឺជាព្រះវិហាររបស់ ព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះជាម្ចាស់បានប្រទានដល់លោកអ្នក។ នេះមាន ន័យថា លោកអ្នកមិនមែនជាម្ចាស់របស់រូបកាយលោកអ្នកទេ ប៉ុន្តែព្រះអង្គ ទៅវិញទេគឺជាម្ចាស់ ព្រោះទ្រង់បានបង់ថ្លៃយើងដោយព្រះជន្មនៃព្រះបុត្រា តែមួយអង្គគត់របស់ទ្រង់។ ហេតុផលដ៏ល្អមួយក្នុងការដែលលោកអ្នកមិន គួរបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសគឺត្រង់ថា៖ រូបកាយ របស់លោកអ្នក គឺជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ (១៩ក)។ ប្រធានបទ ដែលនិយាយអំពីព្រះវិហារ គឺជាប្រធានបទដ៏ធំមួយនៅក្នុងទេវវិទ្យានៃព្រះ គម្ពីរ។ ការស្វែងយល់អំពីរបៀបដែលព្រះវិហារមានភាពស៊ីចង្វាក់គ្នាទៅនឹង សាច់រឿងនៅក្នុងព្រះគម្ពីរទាំងមូល នឹងបង្ហាញឲ្យយើងឃើញកាន់តែច្បាស់ អំពីអត្ថន័យត្រង់ ខ១៩ក ថា «រូបកាយអ្នករាល់គ្នាជាព្រះវិហារនៃព្រះវិញ្ញាណ បរិសុទ្ធ»។ វាមិនសមទៀយដែលលោកអ្នកបណ្តោយខ្លួនទៅមើលរូបដែល ពុំគប្បី នៅទីកន្លែងដែលបរិសុទ្ធបំផុត ដែលជារូបកាយរបស់លោកអ្នក។

ដូច្នេះ ចូរកុំធ្វើវាឲ្យសៅហ្មងឡើយ ហើយចូររក្សាវាឲ្យបានស្អាត ព្រោះវាជាបន្ទប់មួយដ៏បរិសុទ្ធ។

ឃ្លាចុងក្រោយត្រង់ ខ២០ខ ថា «ចូរតម្កើងព្រះនៅក្នុងរូបកាយ» ជាឃ្លានៃសេចក្តីសន្និដ្ឋានលើ ខ១៨គ ដល់ ខ២០ ក៏ដូចជាអត្ថបទទាំងមូលផងដែរ។ ដូច្នេះ នេះជារបៀបមួយក្នុងការសង្ខេបចំណុចស្នូលក្នុងការរំលែកញែករបស់សាវ័ក ប៉ុល នៅក្នុង ខ១២ ដល់ ខ២០ថា៖ *ចូរថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈរូបកាយរបស់លោកអ្នក ដោយកុំកំផិតខាងឯផ្លូវភេទឡើយ។* នៅពេលដែលលោកអ្នកបណ្តោយខ្លួនទៅ មើលរូបភាព ឬវីដេអូអាសអាភាសនោះមានន័យថា លោកអ្នកបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់ផ្ទាល់ ព្រោះទ្រង់ជាម្ចាស់លើរូបកាយរបស់លោកអ្នក។ ការបណ្តោយខ្លួនទៅមើលរូបភាពពុំគួរគប្បី មិនមែនជាការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ តាមរយៈរូប-កាយរបស់លោកអ្នកនោះទេ។

## ៣. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការសប្បាយដ៏ពិសពុល និងមិនស្ថិតស្ថេរ

លោក ម៉ូសេ ពុំបានជ្រើសរើសយក «សេចក្តីអំណរខាងអំពើបាបដែលនៅតែមួយភ្លែត» នោះទេ។ នេះមានន័យថា អំពើបាបអាចនាំឲ្យយើងមានអំណរតិចតួចក្នុងរយៈពេលដ៏ខ្លីមួយ ប៉ុន្តែក្រោយមកក៏រសាយអស់ទៅវិញ។ បន្ទាប់ពីនោះមកគឺជាវិប្បដិសារីដែលនឹងតោងយើងកាន់តែជាប់ស្អិត៖

«ដោយសារជំនឿ លុះលោកធំហើយ នោះលោកមិនព្រមឲ្យគេហៅខ្លួន ជា

កូនរបស់បុត្រីផារ៉ោនទេ លោកស៊ូរងទុក្ខលំបាកជាមួយនឹងរាស្ត្ររបស់ព្រះ ជា-ជាងមានសេចក្តីអំណរខាងអំពើបាប ដែលនៅតែ១ភ្លែតនោះវិញ ដោយបានរាប់សេចក្តីដំនៀលដែលគេតិះដៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិប្រ-សើរជាងអស់ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសម្លឹងចំទៅឯរង្វាន់វិញ» (ហេព្រើរ ១១:២៤-២៦)។

ការបណ្តោយខ្លួនទៅមើលរូបភាពដែលពុំគប្បី គឺជាការដែលនាំឲ្យលោកអ្នកទទួលបានភាពអរសប្បាយភ្លាមៗ ប៉ុន្តែភាពអរសប្បាយនោះមានរយៈពេលត្រឹមតែមួយភ្លែតប៉ុណ្ណោះ។ ក្រោយមក លោកអ្នកនឹងមានអារម្មណ៍ថា គ្មានសេសសល់អ្វី គ្មានភាពស្កប់ស្កល់ ហើយលោកអ្នកនឹងចង់បានថែមទៀតដោយមិនចេះចប់ មិនចេះហើយ។

តើព្រះជាម្ចាស់អាចលើកយកសម្តីនេះ ហើយមានបន្ទូលមកកាន់លោក-អ្នកអំពីការមើលរូបភាព ឬ វីដេអូអាសអាភាសបានដែរឬទេ? យើងអាចសម្រាយខគម្ពីរនោះដូចតទៅ៖

«ដោយសារជំនឿ លោកអ្នកមិនព្រមបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសឡើយ ព្រោះលោកអ្នកជ្រើសរើសយកការដែលមានអំ-ណរក្នុងព្រះជាម្ចាស់ ជាជាងការអរសប្បាយក្នុងការមើលរូបភាពពុំគប្បី ដែលមានការអរសប្បាយក្លាយជាទុក្ខក្នុងរយៈពេលតែមួយភ្លែតនោះ។ លោកអ្នកបានជ្រើសរើសបែបនោះ ដោយសារលោកអ្នកបានយកការមានអំណរក្នុងព្រះជាម្ចាស់ទុកជាទ្រព្យសម្បត្តិដែលប្រសើរ ជាជាងការដែលទៅមើលរូប-ភាព ឬវីដេអូអាសអាភាសដែលគ្រាន់តែអាចផ្តល់ការអរសប្បាយតែមួយ

ភ្លែត ព្រោះលោកអ្នកបានសម្លឹងឆ្ពោះទៅឯរង្វាន់វិញ»។

ការបណ្ដោយខ្លួនទៅមើលរូបភាពពុំគប្បី គឺដូចជាការញ៉ាំថ្នាំពុលមួយគ្រាប់ដែលមានជាតិស្ករពីខាងក្រៅយ៉ាងដូច្នោះដែរ។ ហេតុអ្វីបានជាលោកអ្នកចង់ស្វែងរកភាពស្កប់ស្កល់ ដើម្បីបំពេញការស្រេកឃ្លានខាងឯសាច់ឈាមរបស់ខ្លួន ដោយផឹកថ្នាំពុលដែលមានជាតិស្ករពីខាងក្រៅ (ការមើលរូបភាព ឬវីដេអូអាសអាភាស) ខណៈពេលដែលលោកអ្នកអាចញ៉ាំម្ហូបអាហារដែលមានឱជារសបានដូច្នេះទៅវិញ? ហេតុអ្វីបានជាលោកអ្នកចង់បំពេញនូវសេចក្ដីប្រាថ្នា ចង់បាននូវភាពអរសប្បាយដោយការផឹកថ្នាំពុលដែលមានជាតិស្ករពីខាងក្រៅ (ការមើលរូបភាព ឬវីដេអូអាសអាភាស) ខណៈពេលដែលលោកអ្នកអាចទទួលបានអំណរមកពីព្រះជាម្ចាស់ដូច្នេះទៅវិញ? ការបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជារឿងមួយដែលល្ងីល្ងើបំផុត ព្រោះវាបង្ហាញថា លោកអ្នកគ្មានប្រាជ្ញាអ្វីសោះឡើយ។ កណ្ឌគម្ពីរ សុភាសិត ៦:៣២ បានចែងថា «តែឯអ្នកណាដែលលួចប្រពន្ធគេ នោះជាអ្នកឥតមានគំនិតឡើយ អ្នកណាដែលប្រព្រឹត្តអំពើយ៉ាងនោះ ឈ្មោះថាចង់បំផ្លាញជីវិតខ្លួនហើយ»។ ការបណ្ដោយខ្លួនទៅមើលរូបភាពពុំគប្បីទាំងនោះ ប្រហែលជាអាចនឹងនាំលោកអ្នកឲ្យមានភាពស្កប់ស្កល់ក្នុងបំណងចិត្តនៃអំពើបាបរបស់ខ្លួនមួយភ្លែត ប៉ុន្តែវានឹងមិននាំឲ្យលោកអ្នកមានភាពស្កប់ស្កល់រហូតឡើយ មិនតែប៉ុណ្ណោះសោត វាថែមទាំងលួចបំផ្លាញអំណររបស់លោកអ្នកថែមទៀតផង។

ដូច្នេះ ចូរកុំប្រាថ្នាចង់បានរូបភាពពុំគប្បីទាំងនោះឡើយ ប៉ុន្តែចូរប្រាថ្នា

ចង់បានព្រះជាម្ចាស់វិញ។ ភាពអរសប្បាយដែលចេញពីការមើលរូបភាព ឬវីដេអូអាសអាភាស គឺពោរពេញទៅដោយភាពពិសពុល ហើយវាស្ថិតនៅបានតែមួយភ្លែតប៉ុណ្ណោះ វាផ្ទុយពីអំណោយរបស់ព្រះជាម្ចាស់ ដែលនឹងស្ថិតនៅអស់កល្បជានិច្ច ហើយនឹងនាំលោកអ្នកឲ្យមានភាពស្កប់ស្កល់ជារៀងរហូត។ «របៀបតយុទ្ធនឹងតម្រេកស្រើបស្រាលក្នុង កាមតណ្ហា គឺការបង្កើនជំនឿលើសេចក្តីសន្យាដ៏អស្ចារ្យ និងមានតម្លៃបំផុត។ សេចក្តីសន្យានោះគឺ អស់អ្នកដែលមានចិត្តបរិសុទ្ធនឹងមើលឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គមានពេញដោយសិរីល្អ និងភាពស្កប់ស្កល់»។ មានមនុស្សជាច្រើនដែលចង់មើលឃើញព្រះជាម្ចាស់ ហើយក៏មានមនុស្សជាច្រើនទៀតដែលពុំបានដឹងពីការនោះដែរ។

ដើម្បីជួយបង្កើននូវការប្រាថ្នាចង់បានព្រះជាម្ចាស់ និងការថ្វាយបង្គំទ្រង់នោះសូមអាន ឬក៏ស្តាប់សេចក្តីអធិប្បាយរបស់លោកគ្រូ ចន ផាភ័រ (John Piper) ដែលមានចំណងជើងជាភាសាអង់គ្លេសដូចនេះថា *Sex and the Supremacy of Christ ។* លោក បានលើកឡើងថា៖

*«ការស្គាល់ភាពឧត្តុង្គឧត្តមរបស់ព្រះគ្រីស្ទនឹងជួយពង្រឹងព្រលឹងវិញ្ញាណយើងឲ្យមាំមួន ហើយការនេះនឹងនាំឲ្យយើងមើលឃើញថា ការរួមដំណេក និងភាពអរសប្បាយដ៏តិចតួចដែលចេញពីការរួមដំណេក គឺពុំមានអ្វីដែលគួរឲ្យអស្ចារ្យនោះឡើយ។* ព្រលឹងវិញ្ញាណដែលទន់ខ្សោយនឹងបណ្តាលឲ្យភាពស្រើបស្រាលក្នុងកាមតណ្ហាមានអំណាចយ៉ាងខ្លាំង។ ព្រលឹងវិញ្ញាណរបស់យើងនឹងរីកលូតលាស់កាន់តែធំឡើង ពេលដែលយើងចាប់យកព្រះ

គ្រីស្ទដែលជាទ្រព្យសម្បត្តិដ៏ធំឧត្តម។ ព្រះជាម្ចាស់បានបង្កើតព្រលឹងវិញ្ញាណរបស់យើង ដើម្បីឲ្យយើងមើលឃើញ និងដើម្បីក្រេបរសជាតិនៃភាពឧត្តុង្គ-ឧត្តមរបស់ព្រះគ្រីស្ទ។ គ្មានអ្វីផ្សេងទៀតដែលអាចធ្វើឲ្យព្រលឹងវិញ្ញាណរបស់យើងរីកលូតលាស់ធំឡើង ក្រៅពីការដែលព្រះជាម្ចាស់បានគ្រោងទុកនោះឡើយ ហើយក៏គ្មានអ្វីដែលអាចនឹងបំបាត់អំណាចនៃតម្រេកស្រើបស្រាលក្នុងកាមតណ្ហារបស់យើងបានដែរ ក្រៅតែពីព្រះជាម្ចាស់ផ្ទាល់...»។

«ក្នុងចំណោមហេតុផលដ៏ធំ និងជាក់លាក់មួយ ដែលយើងខ្ញុំគិតថាជាហេតុផលដែលល្បួងនាំលោកីយ៍ ព្រមទាំងសមាជិកក្រុមជំនុំជាច្រើនឲ្យធ្លាក់ក្នុងតម្រេកនៃកាមតណ្ហា និងការមើលរូបភាពពុំគប្បីនោះគឺ បណ្តាលមកពីយើងបានផ្តាច់ខួរក្បាល និងអារម្មណ៍របស់យើងចេញពីព្រលឹងវិញ្ញាណដ៏នៅអស់កល្បជានិច្ច របស់យើងដែលព្រះជាម្ចាស់បានបង្កើតមក។ នៅក្នុងវប្បធម៌របស់លោកខាងលិច ទាំងអ្នកជឿ និងអ្នកមិនជឿសុទ្ធសឹងតែកំពុងលង់ក្នុងសមុទ្រនៃគំនិតដែលឥតប្រយោជន៍ លង់ទៅនឹងអ្វីដែលមិនសំខាន់ និងគ្មានន័យ ក៏ដូចជាលង់ក្នុងភាពល្ងីល្ងើផងដែរ។ ការផ្សព្វផ្សាយនៅតាមទូរទស្សន៍ និងតាមប៉ុស្តិ៍ វិទ្យុ ការសន្ទនា និងការអប់រំនៅតាមសាលារៀននានា សុទ្ធតែឥតប្រយោជន៍ទាំងអស់ ហើយសៀវភៅគ្រីស្ទបរិស័ទ និងរបៀបនៃការថ្វាយបង្គំក៏សុទ្ធតែឥតប្រយោជន៍ដែរ បើការទាំងអស់នេះមិនបាននាំឲ្យយើងលង់ក្នុងភាពឧត្តុង្គឧត្តមរបស់ព្រះគ្រីស្ទ។ ពួកគេតែងតែផ្តោតចិត្តរបស់ខ្លួនទៅលើការកំសាន្តដែលពុំបានការ ទោះបីពួកគេដឹងថា ព្រះជាម្ចាស់បង្កើតចិត្តរបស់ពួកគេក្នុងគោលបំណង ឲ្យពួកគេលង់នៅក្នុងភាពឧត្តម

របស់ទ្រង់ក៏ដោយ។ យ៉ាងណាមិញ នេះគឺជារឿងមួយដែលគួរឲ្យសោក-ស្ដាយបំផុត ដែលពួកគេស៊ូលង់ក្នុងសមុទ្រនៃការឥតប្រយោជន៍ជាជាងលង់ក្នុងព្រះគ្រីស្ទ។ នេះហើយជាមូលហេតុដែលបណ្ដាលឲ្យមនុស្សជាច្រើនស៊ូលង់ក្នុងការរួមដំណេក ដើម្បីឲ្យខ្លួនមានភាពអរសប្បាយ ជាជាងលង់ក្នុងព្រះគ្រីស្ទ តែធាតុពិតការលង់ក្នុងព្រះគ្រីស្ទ គឺជាហេតុផលដែលនាំឲ្យយើងមានភាពអរសប្បាយដ៏ពិត។

«ហេតុដូច្នេះហើយបានជាពុំមានយុទ្ធសាស្ត្រខាងគំនិតប្រាជ្ញាណាមួយដែលយើងអាចយកមកព្យាបាលការញៀនដ៏អាក្រក់របស់យើងបានឡើយ (ទោះបីជាយើងខ្ញុំគិតថាអាចមានខ្លះៗក៏ដោយ)។ ការព្យាបាលដ៏មានប្រ-សិទ្ធភាពបំផុត គឺការភ្ជាប់គំនិត និងអារម្មណ៍របស់យើងទៅនឹងភាពឧត្តុង្គ-ឧត្ដមដ៏នៅអស់កល្បជានិច្ច និងភាពមិនចេះប្រែប្រួលរបស់ព្រះគ្រីស្ទ»។

## ៤. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការបង្ហិនបង្ហោចជីវិតរបស់ខ្លួន

នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:១៥-១៧ បានចែងថា «ដូច្នេះ ចូរប្រយ័ត្នឲ្យមែនទែនអំពីរបៀបដែលអ្នករាល់គ្នារស់នៅ មិនមែនដូចជាមនុស្សគ្មានប្រាជ្ញាទេ ប៉ុន្តែដូចជាមនុស្សមានប្រាជ្ញាវិញ ទាំងចេះប្រើប្រាស់ពេលវេលាផង ពីព្រោះសម័យនេះអាក្រក់ណាស់។ ដូច្នេះ កុំល្ងង់ឡើយ ចូរយល់អំពីអ្វីដែលជាបំណងរបស់ព្រះអម្ចាស់វិញ»។ ទឹកមួយដំណក់មិនអាចប្រៀប-ផ្ទឹមនឹងមហាសមុទ្រប៉ាស៊ីហ្វិកបានឡើយ យ៉ាងណាមិញ ជីវិតដ៏ខ្លីរបស់

លោកអ្នកនៅលើផែនដីនេះ ក៏ពុំអាចប្រៀបផ្ទឹមនឹងជីវិតរបស់លោកអ្នកនៅក្រោយពេលដែលស្លាប់បានដែរ។ បច្ចុប្បន្ននេះ មានមនុស្សជាច្រើនដែលយើងអាចស្រឡាញ់ បម្រើ និងរៀនសូត្រពីគេ ហើយក៏មានការងារជាច្រើនដែលយើងអាចធ្វើបានដែរ។ ប៉ុន្តែ ទន្ទឹមនឹងនោះ លោកអ្នកទំនងជាកំពុង-តែបង្ហិនបង្ហោចជីវិតរបស់ខ្លួន ដោយចំណាយពេលវេលាទៅមើលរូបភាពឬវីដេអូអាសអាភាសជាជាងចំណាយពេលហែលក្នុងសមុទ្រនៃព្រះគម្ពីរ ក៏ដូចជាការប្រើប្រាស់ពេលវេលា និងលុយរបស់ខ្លួនទៅលើការផ្សព្វផ្សាយដំណឹងល្អនៅក្នុងសង្គមរបស់ខ្លួន និងពិភពលោកទាំងមូលទៅវិញ។ នៅពេលដែលលោកអ្នកបណ្តោយខ្លួនទៅមើលរូបភាពពុំគប្បីទាំងនោះ នោះមានន័យថា លោកអ្នកកំពុងតែចំណាយពេល និងកម្លាំងរបស់ខ្លួន ហើយថែម-ទាំងខ្ជះខ្ជាយ ទាំងលុយកាក់ថែមទៀតផង។ លោកអ្នកបែរជាបង្ហិនបង្ហោចជី-វិតដែលព្រះជាម្ចាស់បានប្រទានឲ្យ ជាជាងប្រើជីវិតនោះទៅបម្រើទ្រង់ឲ្យអស់ពីសមត្ថភាព (២ធីម៉ូថេ ២:២០-២២)។ ជាងនេះទៅទៀត លោកអ្នកកំពុង-តែធ្វើឲ្យក្រុមជំនុំពិការហើយ ព្រោះជាជាងការបម្រើមនុស្សនៅក្នុងក្រុមជំនុំ ឬអ្នកជិតខាងរបស់ខ្លួន លោកអ្នកបែរជាធ្វើដូចលោក អេកានដោយលួចស្រ-ឡាញ់អំពើបាបរបស់ខ្លួនជាជាងសម្លាប់អំពើបាបនោះចោលទៅវិញ (យ៉ូស្វេ ៧:១-២៦)។ លើសពីនេះ លោកអ្នកបែរជាទៅរស់នៅតាមរបៀបជាទាសកររបស់អំពើបាបដោយការទៅមើលរូបភាពពុំគប្បី ជំនួសឲ្យការរស់នៅដោយបម្រើព្រះជាម្ចាស់ដែលមានសេរីភាពក្នុងភាពជាទាសកររបស់ទ្រង់ទៅវិញ (រ៉ូម ៦)។ ម៉្យាងវិញទៀត នៅពេលដែលលោកអ្នកបណ្តោយខ្លួនទៅមើល

រូបភាព ឬវីដេអូអាសអាភាស នោះមានន័យថា លោកអ្នកកំពុងតែរស់នៅដូចជា មនុស្សល្ងីល្ងើ ដូចដែលកណ្ឌគម្ពីរសុភាសិតបានលើកឡើង។ នៅក្នុងកណ្ឌគម្ពីរ ទំនុកដំកើង ៩០:១២ ក៏បានលើកឡើងដែរថា៖ «ដូច្នេះ សូមបង្រៀនឲ្យយើងខ្ញុំចេះកំណត់រាប់ថ្ងៃអាយុនៃយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំមានចិត្តខ្មីឃ្មាតឲ្យបានសតិបញ្ញា»។

## ៥. ការបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការក្បត់ប្រពន្ធកូនខ្លួន

នៅត្រង់ចំណុចនេះ គឺចង់សំដៅទៅលើអ្នកដែលបានរៀបការហើយ ក៏ដូចជាអ្នកដែលនឹងរៀបការផងដែរ។ នៅពេលដែលខ្ញុំបានរៀបការជាមួយចេននី (Jenni) ប្រពន្ធរបស់ខ្ញុំ គឺខ្ញុំបានសន្យាជាមួយគាត់ដូចតទៅនេះ៖ «បង អែនឌី (Andy) ព្រមទទួលយកអូន ចេននី ធ្វើជាភរិយាដោយពឹងលើផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតអាពាហ៍ពិពាហ៍របស់យើង។ បងនឹងស្រឡាញ់អូន ហើយដឹកនាំអូនដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ក្រុមជំនុំ និងបានដឹកនាំក្រុមជំនុំយ៉ាងនោះដែរ។ បងសូមសន្យាថា បងនឹងស្រឡាញ់អូនដោយស្មោះរហូតអស់មួយជីវិតបង»។ នៅត្រង់ពាក្យថា «ស្រឡាញ់ដោយស្មោះ» គឺខ្ញុំចង់សំដៅលើសេចក្ដីស្រឡាញ់ដូចដែលព្រះជាម្ចាស់មានចំពោះយើង។ ចំណែកនៅក្នុងភាសាហេព្រើរ ពាក្យ «ហាសិឌ» (hesed) ត្រូវបានប្រើចំនួន ២៤៨ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យនេះផ្ដោតទៅលើទំនាក់-ទំនងដែលមានការប្ដេជ្ញាចិត្តថា *នឹងស្រឡាញ់គ្នាដោយសម្ដែងនូវទឹកចិត្តដ៏*

*ល្អ*។ នៅពេលដែលយើងនិយាយពាក្យនេះ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ គឺសំដៅទៅលើ*ការសន្យា* ដោយសេចក្ដីស្រឡាញ់យ៉ាងស្មោះត្រង់។ សម្រាប់ខ្ញុំ ខ្ញុំនឹងជ្រើសយកការស្លាប់ជាជាងការក្បត់ប្រពន្ធខ្ញុំ។

ប្រសិនបើលោកអ្នកបណ្ដោយខ្លួនទៅមើលរូបភាពដែលពុំគប្បី នោះមានន័យថា លោកអ្នកមិនស្រឡាញ់ប្រពន្ធទេ។ ជាងនេះទៅទៀត លោកអ្នកក៏កំពុងតែក្បត់នឹងសេចក្ដីសន្យាដែលបានសន្យាថានឹងស្រឡាញ់ប្រពន្ធដោយស្មោះត្រង់ទៀតផង។ លោកអ្នកកំពុងតែផិតក្បត់នឹងនាងហើយ! ហើយក៏កំពុងតែធ្វើឲ្យនាងត្រូវប្រកួតប្រជែងជាមួយរូបភាពផ្សេងៗ ដែលលោកអ្នកមានតម្រេកស្រើបស្រាលក្នុងកាមតណ្ហានោះ ហើយវាក៏អាចនឹងបំផ្លាញជីវិតអាពាហ៍ពិពាហ៍របស់លោកអ្នកបានផងដែរ។ លើសពីនេះ វាក៏នឹងធ្វើឲ្យលោកអ្នកបែកបាក់ជាមួយកូនៗរបស់ខ្លួនផងដែរ។ លោកអ្នកនឹងលែងមានអំណាចខាងសីលធម៌ជាមួយក្រុមគ្រួសារ ហើយកូនៗរបស់លោកអ្នកនឹងរងទុក្ខវេទនាយ៉ាងខ្លាំងដែរ ប្រសិនបើការនេះនាំឲ្យលោកអ្នកឈានទៅដល់ដំណាក់កាលលែងលះគ្នា នោះកូនៗរបស់លោកអ្នកនឹងកាន់តែរងទុក្ខ។ ខ្ញុំពិតជាយល់ពីចំណុចនេះច្បាស់ណាស់ ពីព្រោះឪពុកម្ដាយរបស់ខ្ញុំបានរស់នៅបែកគ្នា ហើយក្រោយមកក៏បានលែងលះគ្នាតាំងតែពីយើងខ្ញុំមានអាយុទើបតែ៩ឆ្នាំមកម្ល៉េះ។

## ៦. ការបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការបំផ្លាញខួរក្បាល និងបញ្ញាចិត្តរបស់ខ្លួន

យើងខ្ញុំនឹងបកស្រាយហេតុផលនេះ ដោយសម្អាងទៅលើចំណុចបួនយ៉ាង៖

១. *ការបណ្ដោយខ្លួនឲ្យទៅមើលរូបភាព ឬវីដេអូអាសអាភាសនឹងបំផ្លាញរបៀបដែលលោកអ្នកគិតអំពីការរួមដំណេក។* ការរួមដំណេកគឺជាអំណោយទានមកពីព្រះជាម្ចាស់ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សប្រុសម្នាក់និងមនុស្សស្រីម្នាក់មានការរួមដំណេកជាមួយគ្នា ក្រោយពេលដែលពួកគេទាំងពីរនាក់បាន សន្យា ហើយបានរៀបការជាមួយគ្នា។ ការរួមដំណេកនៅក្នុងជីវិតអាពាហ៍ពិពាហ៍ គឺជារឿងដ៏ល្អប្រពៃ។ ព្រះអង្គ គឺជាអ្នកបង្កើតឲ្យមានការរួមដំណេកឡើង ហេតុដូច្នេះហើយ យើងគួរតែសរសើរទ្រង់អំពីការនោះ។ រូបភាពដែលពុំគប្បី គឺជាការបង្ខូច ហើយបំផ្លាញការរួមដំណេកទៅជាការអាក្រក់។ ប្រសិនបើលោកអ្នកបណ្ដោយខ្លួន នោះលោកអ្នកនឹងគិតអំពីការរួមដំណេកក្នុងលក្ខណៈបែបអាក្រក់ ហើយប្រសិនបើលោកអ្នកបានរៀបការរួចហើយ តែលោកអ្នកបានបណ្ដោយខ្លួនទៅមើលរូបភាពដែលពុំគប្បីទាំងនោះ នោះវានឹងធ្វើឲ្យលោកអ្នកកាន់តែលែងមានអំណរជាមួយប្រពន្ធរបស់ខ្លួន នៅពេលរួមដំណេកជាមួយគ្នាទៀតផង។

២. *ការបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសនឹងបំផ្លាញរបៀបដែលលោកអ្នកគិតអំពីមនុស្សស្រី។* ព្រះជាម្ចាស់បានបង្កើតមនុស្សស្រីមកដូចរូបអង្គទ្រង់ ហើយពួកគាត់ក៏បង្ហាញពីសិរីល្អរបស់ទ្រង់បានយ៉ាងស្រស់ស្អាតផង។ យ៉ាងណាមិញ ប្រសិនបើលោកអ្នកមានតម្រេក

ស្រើបស្រាលក្នុងកាមតណ្ហា ដោយប្រាថ្នាចង់បានខ្លួនរបស់មនុស្សស្រី នោះមានន័យថា លោកអ្នកកំពុងតែគិតថា មនុស្សស្រីគ្រាន់តែជាឧបករណ៍រួមដំណេកសម្រាប់បំពេញកាមតណ្ហាដែលពោរពេញដោយអំពើបាបរបស់លោកអ្នក ជាជាងការដែលគិតថាពួកគាត់ជារូបអង្គនៃព្រះដូចលោកអ្នកដែរ។

៣. *ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសនឹងបំផ្លាញរបៀបដែលលោកអ្នកគិត បំផ្លាញខួរក្បាលរបស់លោកអ្នក ហើយវាក៏នឹងប្តូររបៀបគិតរបស់លោកអ្នកដែរ។* សរុបមក វានឹងបង្វែរ ហើយធ្វើឲ្យសេចក្តីស្រឡាញ់របស់លោកអ្នកពុំដូចមុនទៀតឡើយ។

៤. *ជាលទ្ធផល ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសនឹងបំផ្លាញពីរបៀបដែលលោកអ្នកគិត និងបញ្ញាចិត្តរបស់ខ្លួន។* បញ្ញាចិត្តរបស់លោកអ្នក គឺជាកន្លែងដែលប្រមូលទុកនូវអ្វីៗដែល លោកអ្នកគិតថា "ត្រូវ" ឬ "ខុស"។ ម៉្យាងវិញទៀត នៅពេលដែលលោកអ្នកបណ្តោយខ្លួនទៅមើលរូបភាពពុំគប្បីទាំងនោះ នោះមានន័យថា លោកអ្នកបានធ្វើឲ្យបញ្ញាចិត្តរបស់ខ្លួនកាន់តែស្ពឹក ដោយលោកអ្នកបានគាបសង្កត់បញ្ញាចិត្តរបស់ខ្លួនដោយបង្ខំឲ្យខ្លួនឯងគិតថា អំពើបាបពុំមែនជាបញ្ហាអ្វីនោះទេ។ មិនយូរមិនឆាប់ ការដែលធ្វើដូចនេះនឹងធ្វើឲ្យលោកអ្នកខូចបញ្ញាចិត្ត រហូតដល់លែងចេះថ្កោលទោសលើខ្លួនឯង នៅពេលដែលខ្លួនប្រព្រឹត្តអំពើបាប។ លោកអ្នកប្រហែលត្រូវវាស់វែងបញ្ញាចិត្តរបស់ខ្លួនជាថ្មីម្តងទៀតទាក់ទងនឹងការមើលរូបភាពទាំងអស់នោះ មិនថាតិចឬច្រើនក្តី។

ក្នុងនាមជាគ្រីស្ទបរិស័ទ លោកអ្នកត្រូវតែកែប្រែចិត្តគំនិតជាថ្មីដោយពឹងអាង

លើព្រះបន្ទូល ពីព្រោះការបណ្តោយខ្លួនទៅមើលរូបភាពមិនគប្បី នឹងស៊ីបំផ្លាញចិត្តគំនិត ព្រមទាំងបញ្ញាចិត្តរបស់ខ្លួនផងដែរ។

## ៧. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការរួមចំណែកក្នុងការជួញដូរផ្លូវភេទ

នៅពេលដែលលោកអ្នកបានបណ្តោយខ្លួនចូលរួមមើលរូបភាពដែលពុំគប្បី នោះមានន័យថា *លោកអ្នកកំពុងតែគាំទ្រការរកស៊ីខាងឯផ្លូវភេទរបស់ពួកគេដែរ។* មួយវិញសោត ការរកស៊ីបែបនេះនឹងនាំឲ្យមានការឈឺចាប់ដល់មនុស្សស្រីជាច្រើន។ ការដែលបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស ការនោះនឹងធ្វើឲ្យមនុស្សស្រីមានការឈឺចាប់ ពីព្រោះការនោះវាបានបង្ខូចរបៀបដែលស្ត្រីគិតពីខ្លួនឯង។ មានស្ត្រីជាច្រើនមានការព្រួយបារម្ភ អំពីរូបរាងកាយរបស់ខ្លួន ហើយអ្នកខ្លះបានស្អប់ខ្លួនឯងទៀតផង។ ចំណែកឯស្ត្រីខ្លះទៀតទៅជាបាយមិននឹកទឹកមិនស្រេក ហើយខ្លះទៀតមានជំងឺផ្លូវចិត្ត ពីព្រោះពួកគេមិនអាចប្រជែងជាមួយស្តង់ដារនៃរូបភាព ឬវីដេអូទាំងនោះបានឡើយ។

ក៏ប៉ុន្តែ រូបភាពដែលពុំគប្បីនេះថែមទាំងធ្វើឲ្យស្ត្រីជាច្រើនមានការឈឺចាប់លើសហ្នឹងទៅទៀត នៅ ពេលដែលលោកអ្នកបានបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូដែលពុំគប្បីទាំងនោះ គឺមានន័យថាៈ *លោកអ្នកកំពុងតែបានរួមចំណែកក្នុងការជួញដូរផ្លូវភេទយ៉ាងដូច្នោះដែរ។* រូបភាព ឬក៏វីដេអូអាសអាភាស ជាការដែលនាំឲ្យមានការជួញដូរផ្លូវភេទ វាប្រៀបដូចជាសាំង

ម៉ូតូយ៉ាងដូច្នោះដែរ។ សាំងធ្វើឲ្យម៉ូតូជិះទៅមុខបាន ហើយរូបភាព ឬក៏រឿងអាសអាភាស គឺជាសាំងដែលនាំឲ្យមានការជួញដូរផ្លូវភេទមានដំណើរទៅមុខបានដូចគ្នាដែរ។

## *៧.១. តើអ្វីទៅជាទាសករផ្លូវភេទ?*

ទាសករផ្លូវភេទ គឺជាបុគ្គលដែលជាកម្មសិទ្ធិ ហើយត្រូវបានគ្រប់គ្រងដោយជនម្នាក់ទៀត ហើយជនដែលជាម្ចាស់នោះបានបង្ខំឲ្យបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនប្រព្រឹត្តការរួមដំណេកតាមបង្គាប់របស់ខ្លួន ដើម្បីឲ្យគាត់ដែលជាម្ចាស់អាចទទួលបានលុយ។ មួយវិញទៀត ទាសករផ្លូវភេទ គឺជាការជួញដូរផ្លូវភេទ ដែលបានរាប់បញ្ចូល ទាំងការទទួល ការដឹកជញ្ជូន ព្រមទាំងការកេងប្រវ័ញ្ចប្រយោជន៍ពីទាសករទាំងនោះ។

ស្ត្រីពេស្យាភាគច្រើន គឺជាទាសករផ្លូវភេទ។ ជាទូទៅ ម្ចាស់នៃទាសករតែង-តែរំលោភបំពានលើផ្លូវ កាយ និងផ្លូវចិត្តរបស់ស្ត្រីទាំងនោះ ដោយបង្ខំពួកគេឲ្យបន្តសកម្មភាពរកស៊ីផ្លូវភេទតទៅទៀត។ ជាងនេះ ទៅទៀត នៅពេលខ្លះក៏មានមនុស្សលួចចាប់ពង្រាត់ក្មេងស្រីៗ ឬក្មេងស្រីៗជំទង់ ហើយបង្ខំពួកគេឲ្យធ្វើជា ស្ត្រីពេស្យាទៀតផង។ ភាគច្រើននៃស្ត្រីដែលរកស៊ីផ្លូវភេទ សុទ្ធសឹងតែត្រូវបានគេរំលោភបំពានខាងផ្លូវ ភេទរួចទៅហើយ។ ចំណែកឯស្ត្រីដែលលក់ខ្លួន (ដែលជាក្មេងស្រី ឬក្មេងស្រីជំទង់) គឺសុទ្ធតែមានការបារម្ភអំពីខ្លួនឯង និងមានជម្ងឺផ្លូវចិត្ត ហើយមិនឲ្យតម្លៃខ្ពស់លើខ្លួនឯងដែរ។

## *៧.២. តើរូបភាព និងវីដេអូអាសអាភាសគឺជាសាំងសម្រាប់ការជួញដូរផ្លូវភេទយ៉ាងដូចម្ដេច?*

រូបភាព ឬវីដេអូអាសអាភាសគឺជាប្រេងសាំងដែលបញ្ឆេះឲ្យកាន់តែមានស្ត្រីពេស្យា និងបង្កើតឲ្យមាន ការជួញដូរផ្លូវភេទកាន់តែច្រើនឡើងៗ។ ខ្ញុំពុំដែលឮនរណានិយាយរ៉េកញែកអំពីចំណុចទាំងនេះឲ្យបានច្បាស់លាស់ ហើយងាយស្រួលជឿជាងលោកគ្រូ ដាវីឌ ផ្លាត (David Platt) ឡើយ។ នៅក្នុងជំពូក៥ នៃសៀវភៅរបស់លោក ដែលមានចំណងជើងជាភាសាអង់គ្លេសថា *Counter Culture* ហើយសៀវភៅនេះបានរៀបរាប់ទាក់ទងនឹងក្មេងស្រីម្នាក់ដែលមានអាយុ ៩ឆ្នាំ នាងរស់នៅភាគខាងជើងនៃប្រទេសនេប៉ាល់ នាងមានឈ្មោះថា ម៉ាលីហា (Maliha)។ មានថ្ងៃមួយ មានមេខ្យល់ដ៏ពូកែម្នាក់បានមកបោកប្រាស់ម្ដាយរបស់ម៉ាលីហា ដែលជាស្ត្រីមេម៉ាយដ៏ក្រីក្រម្នាក់ ដោយបានសន្យាថានឹងជួយផ្គត់ផ្គង់គ្រួសាររបស់គាត់ ក៏ដូចជាជួយរកការងារដែលផ្ដល់ប្រាក់ខែខ្ពស់សម្រាប់ម៉ាលីហានៅជើងភ្នំហិម៉ាល័យ (Himalayan)។ មេខ្យល់នោះបានសន្យាថា នឹងផ្ញើលុយដែលម៉ាលីហារកបានឲ្យម្ដាយនាង ហើយនាំម៉ាលីហាមកលេងផ្ទះយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ។ មិនយូរមិនឆាប់ ម្ដាយរបស់ម៉ាលីហាក៏បានយល់ព្រមឲ្យកូនស្រីទៅធ្វើការ ទោះបីជាគាត់ត្រូវបង្ខំចិត្តក៏ដោយ ក៏ប៉ុន្តែមេខ្យល់នោះពុំបានរក្សាពាក្យសន្យារបស់ខ្លួនឡើយ។ ការងារថ្មីរបស់ម៉ាលីហានាពេលនោះ គឺត្រូវអង្គុយនៅមុខហាងមួយនៅក្នុងទីក្រុង ហើយកន្លែងនោះមានមនុស្សប្រុសជាច្រើនដែលបានមករំលោភបំពាន ទៅលើក្មេងស្រីដ៏កម្សត់ និងស្រស់ស្អាតម្នាក់នោះ។ នៅថ្ងៃខ្លះ

មានមនុស្សប្រុសរហូតដល់ទៅ២០នាក់បានមករំលោភបំពានលើម៉ាលីហា។

បន្ទាប់ពីបានរៀបរាប់រឿងរ៉ាវរបស់ម៉ាលីហារួច លោកគ្រូបានរៀបរាប់រឿងរបស់នាងហាណា (Hannah) ដែលមានអាយុ ១៦ឆ្នាំ។ នាងរស់នៅក្នុងទីក្រុងប៊ើរមិងហែម រដ្ឋអាឡាបាម៉ា ប្រទេសអាមេរិក (Birmingham, Alabama, USA)។ សង្សាររបស់នាងបានយកចិត្តទុកដាក់លើរូបនាងដូចជាម្ចាស់ក្សត្រី ហើយបានលួងលោមនាងឲ្យរត់ជាមួយគ្នា ទៅទីក្រុងឡូស៍ អានជើលេស៍ (Los Angeles) ដើម្បីឲ្យនាងបានធ្វើជាអ្នកបង្ហាញម៉ូត។ បន្ទាប់មក សង្សាររបស់នាងបានល្បួងនាងឲ្យថតរូបអាក្រាត និងក្រោយមកគេក៏បានបង្ខំនាងឲ្យដេកជាមួយអ្នកបើកឡាន។ មិនយូរប៉ុន្មាន សង្សាររបស់នាងក៏បានក្លាយជាមេខ្យល់ជួញដូរនាង។

នៅក្នុងសម្រង់សម្ដីនៃសេចក្ដីខាងក្រោមនេះ លោកគ្រូ ដាវីឌ បានលើកឡើងអំពីចំណុចដែលបានបង្ហាញថា រូបភាព ឬវីដេអូអាសអាភាស មានការប្រាស្រ័យទាក់ទងជាមួយការជួញដូរផ្លូវភេទ៖

“ការស្រាវជ្រាវនៅតែបន្តបង្ហាញឲ្យឃើញពីការជាប់ទាក់ទងគ្នារវាងការជួញដូរផ្លូវភេទ និងការផលិតរូបភាព ឬវីដេអូអាសអាភាស។ ច្បាប់ក៏បានទទួលស្គាល់ពីចំណុចនេះដែរ ហើយអ្នកដែលបានផលិតរូបភាព ឬវីដេអូអាសអាភាសក៏បានទទួលស្គាល់ដូចគ្នា។ ទោះបីជាយើងពុំបានដឹងអំពីតួលេខច្បាស់លាស់ក៏ដោយ ក៏អ្នកស្រាវជ្រាវខាងផ្លូវភេទ បានលើកឡើងដែរថា យ៉ាងហោចណាស់មួយភាគបីនៃអ្នកដែលត្រូវបានគេជួញដូរ ត្រូវគេបង្ខំឲ្យចូលរួមក្នុងការផលិតរូបភាព ឬវីដេអូអាសអាភាសទាំងអស់នោះ។

ការស្រាវជ្រាវមួយទៀតក៏បានលើកឡើងស្រដៀងគ្នានោះដែរ ទាក់ទងនឹងស្រ្តីពេស្យា ការផលិតរូបភាព ឬវីដេអូអាសអាភាស និងការជួញដូរផ្លូវភេទថា៖ ៥០% នៃស្រ្តីពេស្យាគឺប្រមាណ៩០០ នាក់នៅក្នុងប្រទេសចំនួនប្រាំបួនបានផ្តល់ព័ត៌មានថា ពួកគាត់ត្រូវបានគេបង្ខំឲ្យថតរូប ឬវីដេអូអាសអាភាសនៅពេលដែលគាត់នៅធ្វើជាស្រ្តីពេស្យា។ នៅពេលដែលបានឮ ឬបានអានព័ត៌មានបែបនេះ នោះចូរកុំមើលរំលងភាពស្របគ្នារវាងការជួញដូរផ្លូវភេទនិងការផលិតរូបភាព ឬវីដេអូដែលពុំគប្បីឡើយ។ មនុស្សប្រុស ឬមនុស្សស្រីដែលបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូដែលពុំគប្បី គឺសុទ្ធសឹងតែជាអ្នកដែលកំពុងទាមទារឲ្យមានការរកស៊ីខាងផ្លូវភេទ និងក្លាយទៅជាសាំងសម្រាប់ការជួញដូរផ្លូវភេទផងដែរ»។

«ប៉ុន្តែវដ្តរបស់វាគឺអាក្រក់ជាងនេះទៅទៀត ពីព្រោះនៅពេលដែលមានអ្នកមើលរូបភាពពុំគប្បីទាំងនោះកាន់តែច្រើន នោះនឹងមានអ្នកចង់បំពេញភាពស្កប់ស្កល់របស់ខ្លួនដោយទៅរកស្រ្តី ឬបុរសពេស្យាឲ្យកាន់តែច្រើនដែរ។ បំ-ណងប្រាថ្នាបែបនេះ នឹងនាំឲ្យមានមនុស្សប្រុសស្រីកាន់តែច្រើនប្រឡូកក្នុងការរកស៊ីផ្លូវភេទ ពីព្រោះគ្រឿងអេឡិចត្រូនិករបស់យើងនៅតាមផ្ទះ អាចក្លាយ-ជាតំបន់រកស៊ីផ្លូវភេទដ៏មានសក្តានុពល»។ រូបភាព ឬវីដេអូអាសអាភាស គឺជាសាំងដែលបញ្ឆេះឲ្យមានការរកស៊ីផ្លូវភេទ និងអាចបង្កើតឲ្យមានការជួញដូរផ្លូវភេទកាន់តែច្រើនឡើងៗ»។

«តើយើងយល់ពីអ្វីដែលយើងកំពុងតែធ្វើដែរឬទេ? គ្រប់ពេលដែលមនុស្សប្រុស ឬមនុស្សស្រីណាម្នាក់មើលរូបភាព ឬវីដេអូអាសអាភាស នៅលើ

បណ្ដាញអ៊ីនធឺណិត នោះមានន័យថា ពួកគេបានរួមចំណែកក្នុងការរកស៊ីផ្លូវភេទហើយ ទោះបីជាពួកគេមើលតែម្នាក់ឯងក្នុងគ្រឿងអេឡិចត្រូនិករបស់ខ្លួនក៏ដោយ...»។

«មិនថាយើងគូសសញ្ញាខ្វែងប៉ុន្មានដងនៅលើដៃរបស់យើង ដើម្បីជាសញ្ញាបញ្ឈប់ការជួញដូរផ្លូវភេទនោះទេ ល្គឹកណាយើងនៅតែប្រើដៃដដែលនោះទៅបើកមើលរូបភាពពុំគប្បីទាំងនោះលើបណ្ដាញអ៊ីនធឺណិត នោះមានន័យថា យើងក៏កំពុងតែបោកប្រាស់ខ្លួនឯង ហើយវាជាការបោកប្រាស់ដ៏ធ្ងន់ធ្ងរបំផុត»។

តាមការស្រាវជ្រាវពីសាកលវិទ្យាល័យ ចន ហ៊ូមខិនស៍ (John Hopkins) ក៏បានឯកភាពលើចំណុចនេះដែរ។ លើសពីនេះទៅទៀត ការស្រាវជ្រាវបានអះអាងថា មានចំណុចទាក់ទងគ្នាជាច្រើនរវាងការផលិតរូបភាព ឬវីដេអូអាសអាភាសជាមួយនឹងការជួញដូរផ្លូវភេទ ហើយគេក៏បានលើកឡើងដែរថា ការទប់ស្កាត់ការផលិតរូបភាព ឬវីដេអូអាសអាភាសអាចនឹងកាត់បន្ថយអត្រានៃការជួញដូរផ្លូវភេទបាន។

មានភស្តុតាងជាច្រើនដែលបានបង្ហាញអំពីចំណុចនេះ។ ស្ត្រីដែលបានរត់គេចពីការជួញដូរផ្លូវភេទ តែងតែអះអាងថា ការផលិតរូបភាព ឬវីដេអូអាសអាភាស គឺជាសាំងដែលនាំឲ្យមានការជួញដូរផ្លូវភេទឆ្ពោះទៅមុខ។ មេខ្យល់តែងតែបង្ខំស្ត្រីទាំងនោះឲ្យថតរូបអាក្រាត ឬវីដេអូអាសអាភាស ហើយក៏បង្ខំឲ្យពួកគេធ្វើពុតជាខ្លួនកំពុងតែសប្បាយពេលកំពុងថត។ ស្ត្រីដែលនៅក្នុងរូបភាពភាគច្រើន គឺសុទ្ធសឹងតែជាទាសករផ្លូវភេទ ហើយមេខ្យល់ក៏បានប្រើ-

ប្រាស់រូបភាពទាំងនោះ ដើម្បីបង្រៀនក្មេងស្រីៗអំពីរបៀបរួមដំណេកទៀតផង។

ការដែលលោកអ្នកបណ្ដោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស មានន័យថា លោកអ្នកកំពុងតែរួមចំណែកក្នុងការចាក់សាំងបញ្ឆេះឲ្យមានស្ត្រី ឬបុរសពេស្យា និងការជួញដូរផ្លូវភេទ ក៏ដូចជារូបភាព និងវីដេអូទាំងនោះដែរ។ នេះគឺជាចំណែកមួយនៃការផ្គត់ផ្គង់នូវតម្រូវការក្នុងការបង្កើតឲ្យមានអំពើពេស្យា និងការជួញដូរផ្លូវភេទ។

ចូរចងចាំចំណុចនេះឲ្យបានច្បាស់នៅក្នុងបញ្ញាចិត្តរបស់លោកអ្នក៖ *ដោយសារការផលិតរូបភាពពុំគប្បីទាំងនោះវាជាគ្រឿងបញ្ឆេះឲ្យមានការជួញដូរផ្លូវភេទ ដូច្នេះការបណ្ដោយខ្លួនឲ្យមើលរូបភាព ឬវីដេអូអាសអាភាសក្នុងកម្រិតណាក៏ដោយ គឺជាការរួមចំណែកក្នុងការជួញដូរផ្លូវភេទ ព្រោះជនដែលលោកអ្នកកំពុងមើលដោយមានតម្រេកស្រើបស្រាល កំពុងតែទទួលបានកម្រៃចេញពីរូបភាពទាំងនោះ។* ហើយចំណុចសំខាន់នោះ គឺគ្រប់រូបភាព ឬវីដេអូទាំងអស់សុទ្ធតែមានចំណែកក្នុងការធ្វើជាសាំងបញ្ឆេះឲ្យមានអំពើពេស្យា និងការជួញដូរផ្លូវភេទ។

## *៧.៣. តើមនុស្សប្រុសគួរគិតដូចម្ដេចទាក់ទងនឹងរូបភាព និងវីដេអូអាសអាភាស?*

តើការធ្វើជាមនុស្សប្រុសមានអត្ថន័យយ៉ាងដូចម្ដេច? លោកគ្រូ ចន ផាភ័រ បានផ្ដល់អត្ថន័យ យ៉ាងល្អទាក់ទងនឹងភាពពេញលក្ខណៈរបស់មនុស្សប្រុស ហើយខ្ញុំគិតថា គ្មាននរណាម្នាក់អាចផ្ដល់អត្ថន័យបានល្អជាងលោកឡើយ៖

“ចំណុចស្នូលនៃភាពជាបុរសពេញលក្ខណៈ គឺជាស្មារតីទទួលខុសត្រូវក្នុងការដឹកនាំ ការផ្គត់ផ្គង់ និងការការពារមើលថែមនុស្សស្រីតាមរបៀបដែលសមស្របទៅនឹងទំនាក់ទំនងផ្សេងៗគ្នារបស់មនុស្សប្រុស”។ ត្រង់ចំណុចនេះពុំមែនមានន័យថា មនុស្សប្រុសពូកែហែលទឹកជាងមនុស្សស្រីនោះទេ ប៉ុន្តែមនុស្ស ប្រុសចង់បង្ហាញការផ្តល់កិត្តិយសដ៏ជ្រាលជ្រៅបំផុតដល់មនុស្សស្រីនិងក្មេងៗ។ ម្យ៉ាងទៀត ការប្រឈមមុខនឹងគ្រោះថ្នាក់ ដើម្បីការពារមនុស្សស្រី គឺជាកាតព្វកិច្ចរបស់មនុស្សប្រុស។ មួយវិញទៀត មនុស្សប្រុសពេញលក្ខណៈនឹងបានដឹងដោយខ្លួនឯងថា ក្នុងនាមជាបុរស ព្រះជាម្ចាស់បានត្រាស់ហៅគាត់ឲ្យមានការនាំមុខក្នុងការការពារមនុស្សស្រីដែលគាត់នៅជាមួយ”។ មួយវិញទៀតសោត មនុស្សប្រុសត្រូវប្រាកដក្នុងបញ្ញាចិត្តថា ខ្លួនមិនត្រូវធ្វើអ្វីដែលនាំឲ្យមនុស្សស្រី ឬក្មេងៗឈឺចាប់ឡើយ។ ការមើលរូបភាព ឬវីដេអូអាសអាភាស គឺជារបៀបមួយដែលធ្វើឲ្យមនុស្សស្រីឈឺចាប់។ ដូចនេះចូរគិតអំពីរូបភាព ឬវីដេអូអាសអាភាស បែបជាមនុស្សប្រុសគ្រប់លក្ខណ៍ចុះ។

ក្រោយពីការអានរឿងរ៉ាវរបស់នាងម៉ាលីហាដែលមានអាយុ៩ឆ្នាំរួចមក តើលោកអ្នកមានចិត្តអាណិតអាសូរចំពោះនាងដែរឬទេ? តើលោកអ្នកមានចិត្តខឹងឃ្នាន់ខ្នាញ់ចំពោះអ្នកដែលគាបសង្កត់នាងដែរឬទេ? មានរឿងរ៉ាវជាច្រើនរាប់លានទៀត ដែលស្រដៀងនឹងរឿងរ៉ាវរបស់នាងម៉ាលីហាដែលត្រូវបានគេជួញដូរផ្លូវភេទ។ តើលោកអ្នកពុំមានអារម្មណ៍ឈឺចាប់ទេឬអី នៅពេលដែលលោកអ្នកបានស្តាប់ឮអំពីការដែលមនុស្សពេញវ័យចាប់កុមារី និងក្មេងស្រីជំទង់យកទៅរំលោភ ឬយកពួកគាត់ទៅធ្វើជាទាសករផ្លូវភេទ? តើ លោកអ្នក

ពុំមានកំហឹងចំពោះអ្នកដែលធ្វើបាបក្មេងៗ និងក្មេងស្រីជំទង់ទាំងនោះទេឬ អី? *លោកអ្នកត្រូវតែមាន អារម្មណ៍ខឹង និងមានអារម្មណ៍ឈឺចាប់ចំពោះអ្នកផលិតរូបភាព ឬវីដេអូអាសអាភាស!* កំហឹងដែលលោកអ្នកមាន នៅពេលដែលលោកអ្នកបានស្តាប់ ឬក៏អានរឿងដែលមនុស្សប្រុសដ៏អាក្រក់បានរំលោភក្មេងស្រីដែលមានអាយុទើបតែ៩ឆ្នាំ។ នេះគឺជាកំហឹងដែលលោក-អ្នកត្រូវតែមានចំពោះអ្នកដែលផលិតរូបភាពមិនល្អទាំងនោះដែរ។ លោក-អ្នកត្រូវតែស្អប់ ហើយប្រឆាំងចំពោះអ្នកផលិតរូបភាព ឬវីដេអូអាសអាភាស ដូចដែលលោកអ្នកបានស្អប់ក្រុមមនុស្សប្រុស ដែលរំលោភលើស្ត្រីដែលទន់ខ្សោយពុំអាចជួយខ្លួនឯងបានយ៉ាងដូច្នោះដែរ។ ហើយប្រសិនបើលោកអ្នកឃើញ មនុស្សប្រុសមួយក្រុមបានព្រួតគ្នារំលោភស្ត្រីតែម្នាក់ តើលោកអ្នកនឹងជួយស្ត្រីនោះ ឬក៏បង្កើតឲ្យខ្លួនឯងមានភាពស្រើបស្រាលឡើង? និយាយឲ្យត្រង់ បើលោកអ្នកមិនទៅជួយស្ត្រីនោះ នោះមានន័យថា លោកអ្នកកំពុងតែបង្កើតឲ្យខ្លួនឯងមានភាពស្រើបស្រាល ដោយមានការរួមចំណែកក្នុងការរំលោភនាងពីចម្ងាយរួចទៅហើយ។

សរុបសេចក្តីមក នៅពេលដែលលោកអ្នកបណ្តោយខ្លួនឲ្យទៅមើលរូបភាព ឬវីដេអូអាសអាភាស នោះមានន័យថា លោកអ្នកកំពុងតែរួមចំណែកក្នុងការជួញដូរផ្លូវភេទ។ ការផលិតរូបភាព និងវីដេអូអាសអាភាស គឺជាការធ្វើបាបមនុស្សស្រី និងក្មេងស្រីៗ ព្រោះវាបង្កើតឲ្យមានស្ត្រី ឬបុរសពេស្យា និងការជួញដូរផ្លូវភេទ។ មនុស្សប្រុសដែលចេះផ្តល់កិត្តិយសដល់មនុស្សស្រី គឺជាមនុស្សប្រុសដែលការពារ និងមិនធ្វើបាបស្ត្រី និងក្មេងស្រីៗ។

## សេចក្តីបញ្ចប់

ហេតុផលប្រាំពីរយ៉ាងដែលលោកអ្នកមិនគួរបណ្តោយខ្លួនទៅមើលរូប-ភាពអាសអាភាសៈ

*១. ការបណ្តោយខ្លួនមើលរូបភាព ឬវីដេអូអាសអាភាសនឹងបណ្តាលឲ្យលោកអ្នកធ្លាក់នរក។*

*២. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសមិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់ក្នុងរូបកាយរបស់លោកអ្នកឡើយ។*

*៣. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការសប្បាយដ៏ពិសពុល និងមិនស្ថិតស្ថេរ។*

*៤. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសគឺជាការបង្ហិនបង្ខោចជីវិតរបស់ខ្លួន។*

*៥. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសគឺជាការក្បត់ប្រពន្ធកូនខ្លួន។*

*៦. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសគឺជាការបំផ្លាញខួរក្បាល និងបញ្ញាចិត្តរបស់ខ្លួន។*

*៧. ការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស គឺជាការរួមចំ-ណែកក្នុងការជួញដូរផ្លូវភេទ។*

## សេចក្តីអធិស្ឋាន

ឱ! ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ ទូលបង្គំសូមអរគុណព្រះអង្គ ដែលព្រះគុណរបស់ទ្រង់បង្រៀនទូលបង្គំឲ្យចេះបដិសេធនូវអ្វីដែលទ្រង់មិនសព្វព្រះហឫទ័យ និងតម្រេកស្រើបស្រាលក្នុងកាមតណ្ហាបែបលោកីយ៍ ដែលមានដូចជាការបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសជាដើម។ ទូលបង្គំសូមអរព្រះគុណព្រះអង្គដែលទ្រង់ប្រទានព្រះគុណដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចរស់នៅដោយចេះគ្រប់គ្រងចិត្តរបស់ខ្លួនឯង និងធ្វើអ្វីត្រឹមត្រូវ ព្រមទាំងចេះកោតខ្លាចទ្រង់នៅក្នុងយុគសម័យនេះ ខណៈពេលដែលទូលបង្គំទន្ទឹងរង់ចាំសេចក្តីសង្ឃឹម ដែលមានពេញដោយព្រះពរ គឺជាការដែលព្រះយេស៊ូវគ្រីស្ទជាព្រះដ៏អស្ចារ្យ និងជាព្រះអង្គសង្គ្រោះរបស់យើង ទ្រង់នឹងយាងត្រឡប់មកវិញក្នុងសិរីល្អរបស់ទ្រង់។ អរព្រះគុណព្រះយេស៊ូវដែលបានសុគតជំនួសទូលបង្គំ ដើម្បីនឹងសង្គ្រោះទូលបង្គំចេញពីអំពើបាបដែលមានដូចជាការមើលរូបភាព ឬវីដេអូអាសអាភាសជាដើម។ ដ្បិតទ្រង់ក៏បានសុគត ដើម្បីនឹងបន្សុទ្ធពួកយើងដែលជារាស្ត្ររបស់ទ្រង់ផ្ទាល់ ដើម្បីឲ្យពួកយើងឧស្សាហ៍ធ្វើការល្អដែរ។ ឱព្រះអង្គអើយ ទូលបង្គំពិតជាត្រូវការព្រះគុណរបស់ទ្រង់ណាស់! សូមព្រះអង្គប្រទានព្រះគុណរបស់ទ្រង់មក ដើម្បីកុំឲ្យទូលបង្គំបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាស ក៏ប៉ុន្តែដើម្បីឲ្យទូលបង្គំអាចរកភាពស្កប់ស្កល់នៅក្នុងទ្រង់វិញ។ អាម៉ែន។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Andrew David Naselli
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក អ៊ុន ជ័យរិទ្ធ, លោក
ជួប ប៊ុនហាក់, លោកគ្រូ ជឿន ជីវិចន្ទា, លោក ឯក ម៉ានិល, លោក ទេព វ៉ូ និងកញ្ញា ថន ស្ថាពរ
ដកស្រង់ខ្លះៗចេញពី http://themelios.thegospelcoalition.org/article/seven-reasons-you-should-not-indulge-in-pornography ដោយមានការអនុញ្ញាត។
លោកអ្នកអាចអានអត្ថបទនេះនៅលើគេហទំព័រ http://plovpit.com/pornography/

# ២

# លទ្ធផលនៃការមើលរូបភាពអាសអាភាសដែលឥតគិតថ្លៃ

លោក ធែរី ក្រូវស៍ (Terry Crews) ជាបុរសម្នាក់ដែលទទួលបានជោគជ័យជាច្រើន៖ គាត់ជាអ្នកលេងបាល់ NFL អាជីព ជាអ្នកថតកុន ហើយបើនិយាយឲ្យខ្លីទៅ គាត់ជាបុរសម្នាក់ដែលមើលទៅអស្ចារ្យខ្លាំងណាស់។ ប៉ុន្តែគាត់ក៏មានលក្ខណសម្បត្តិមួយផ្សេងទៀតដែលខុសពីអ្នកដទៃដែរ៖ នៅក្នុងយុគសម័យនៃភាពពេញនិយមក្នុងការរួមភេទ គាត់បែរជាមានប្រសាសន៍ទាក់ទងនឹងគ្រោះថ្នាក់នៃការមើលរូបអាសអាភាសទៅវិញ។ គាត់បាននិយាយសារភាពនៅក្នុងវីដេអូខ្លីមួយថា "គ្រប់ពេលដែលខ្ញុំមើលរូបភាព ឬក៏វីដេអូអាសអាភាស វាតែងតែមានរនាំងមួយមកឃាំងខ្ញុំ។ វាដូចជាមានដុំឥដ្ឋមួយដុំថែមទៀតមកឃាំងប្រពន្ធខ្ញុំ និងខ្ញុំ"។

ទីបន្ទាល់របស់លោក ហ្គ្រូស៍ (Crews) បានធ្វើឲ្យមានការឆ្លើយតបយ៉ាងខ្លាំងនៅលើប្រព័ន្ធផ្សព្វផ្សាយក្នុងសង្គម (social media)។ មនុស្សជាច្រើនបានកត់សម្គាល់ឃើញពីភាពគ្រោះថ្នាក់នៃការមើលរូបភាព ឬវីដេអូអាសអាភាសដែលប៉ះពាល់ដល់ខ្លួនផ្ទាល់។ តាមពិត គ្មានអ្នកណាអាចនឹងមើលរំលងពីគ្រោះថ្នាក់នៃផលប៉ះពាល់នោះបានឡើយ។ ទំហំនៃគ្រោះថ្នាក់ដោយសារការមើលរូបភាព ឬក៏វីដេអូអាសអាភាស វាធំខ្លាំងណាស់។ សូម្បីតែការមើលរូបភាព ឬក៏វីដេអូអាសអាភាសដោយឥតគិតថ្លៃក៏នៅតែមានផលកម្មខ្ពស់ដែរ។ លើសពីការបង្ខូចខួរក្បាល និងការបំផ្លាញទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ការមើលរូបភាព ឬក៏វីដេអូអាសអាភាសក៏ថែមទាំងរារាំងព័ន្ធកិច្ចរបស់ព្រះយេស៊ូវនៅលើផែនដីនេះដែរ។ ខាងក្រោមនេះជាហេតុផលបីយ៉ាងដែលកើតមកពីការមើលរូបភាព ឬក៏វីដេអូអាសអាភាសដែលអាចរារាំងព័ន្ធកិច្ចរបស់ព្រះយេស៊ូវ ហើយខ្ញុំក៏បានលើកឡើងអំពីក្តីសង្ឃឹមខ្លះៗសម្រាប់យើងទាំងអស់គ្នា ដែលជាមនុស្សមានបាបផងដែរ៖

## ១. ការមើលរូបភាព ឬក៏វីដេអូអាសអាភាសរារាំងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់*នៅក្នុងជីវិតផ្ទាល់ខ្លួន*របស់យើង

ព្រះជាម្ចាស់មានព័ន្ធកិច្ចជាច្រើនដែលទ្រង់ចង់បំពេញតាមរយៈរាស្ត្ររបស់ទ្រង់។ ព្រះអង្គមិនប្រើប្រាស់មនុស្សដ៏ល្អឥតខ្ចោះនៅក្នុងនគររបស់ទ្រង់ឡើយ។ សព្វថ្ងៃនេះ អ្នកជឿគ្រប់រូបដែលបានកើតជាថ្មីហើយត្រូវតែបន្តតយុទ្ធជាមួយ “មនុស្សចាស់” ជាដាច់ខាត (២កូរិនថូស ៥:១៧; កូឡូស

៣:៩-១០)។ យើងចង់បោះបង់អំពើបាបរបស់យើងចោល ប៉ុន្តែលុះត្រាតែព្រះជាម្ចាស់សម្រេចការនេះ ដូច្នេះយើងត្រូវតែបន្តរស់នៅក្នុងការតយុទ្ធតទៅទៀត។ យើងមិនត្រូវព្រងើយកន្តើយចំពោះសាច់ឈាមរបស់យើងនោះឡើយ (រ៉ូម ៨:១៣; កូឡូស ៣:៥)។

ប៉ុន្តែ នៅពេលដែលយើងចុះចូលចំពោះការមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺមានន័យថា យើងបានអនុញ្ញាតឲ្យជីវិតខាងឯព្រលឹងវិញ្ញាណរបស់យើងចុះខ្សោយហើយ។ បើនិយាយឲ្យខ្លីទៅ ខ្ញុំមិនដែលឮអ្នកជឿព្រះយេស៊ូវលើកឡើងថា គាត់កំពុងតែមានភាពឆេះឆួលក្នុងការសិក្សាព្រះគម្ពីរ និងក្នុងការអធិស្ឋាន នៅពេលដែលគាត់កំពុងបំពេញចំណង់ចិត្តរបស់គាត់ខាងឯសាច់ឈាមម្តងហើយម្តងទៀតនោះទេ។ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងម្នាក់ៗ អំពើបាបតែងតែនាំឲ្យយើងបរាជ័យ ពោលគឺមិនមែនគ្រាន់តែក្នុងចំណុចបរិសុទ្ធរបស់យើងខាងឯផ្លូវភេទនោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យយើងបរាជ័យក្នុងគ្រប់ជ្រុងជ្រោយនៃជីវិតបរិសុទ្ធទាំងមូលផងដែរ (រ៉ូម ១២:២; ១ថែស្សាឡូនីច ៤:៣)។ ការមើលរូបភាព ឬក៏វីដេអូអាសអាភាសនឹងបង្វែរចិត្តលោកអ្នកឲ្យលែងអើពើចំពោះប្តីប្រពន្ធខ្លួន ហើយយើងក៏នឹងចាប់ផ្តើមឈប់រវីរវល់ចំពោះកូនចៅដែរ។ យើងនឹងឈប់ឈោងចាប់អ្នកមិនជឿនៅកន្លែងធ្វើការ ក៏ដូចជាអ្នកជិតខាងរបស់យើងដែរ ព្រោះយើងដឹងថា យើងកំពុងតែរស់នៅក្នុងសេចក្តីកុហក និងភាពរអៀសខ្លួន។ ការដែលយើងព្យាយាមបំពេញភាពស្កប់ស្កល់ខាងឯភាពត្រេកត្រអាលរបស់យើងនឹងរារាំងទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយព្រះគ្រីស្ទ។

## ២. ការមើលរូបភាព ឬក៏វីដេអូអាសអាភាសរារាំងព័ន្ធកិច្ច របស់ព្រះជាម្ចាស់*នៅក្នុងជីវិតក្រុមជំនុំ*របស់យើង

នៅពេលដែលសមាជិកណាម្នាក់ក្នុងក្រុមជំនុំ ចុះចូលចំពោះការបំពេញបំណងប្រាថ្នារបស់ខ្លួនខាងឯសាច់ឈាម នោះមានន័យថា គាត់បានបន្ថយភាពរស់រវើកនៅក្នុងក្រុមជំនុំនោះហើយ។ អ្នកដឹកនាំក្នុងក្រុមជំនុំណាដែលមើលរូបភាព ឬក៏វីដេអូអាសអាភាសជាទម្លាប់នឹងឈប់មើលថែចៀមរបស់ខ្លួន ព្រោះគាត់បានឈប់មើលថែខ្លួនឯងហើយ។ ប្រសិនបើសមាជិកដែលមានអំណោយទានក្នុងការបម្រើបែរជាបណ្ដោយខ្លួនឲ្យទៅមើលរូបភាព ឬក៏វីដេអូអាសអាភាសឥតឈប់ឈរ នោះគាត់នឹងចាប់ផ្ដើមលែងមានចិត្តចង់ជួយក្រុមជំនុំ ក៏ដូចជាឈោងចាប់អ្នកមិនទាន់ជឿផ្សេងទៀត។ នៅពេលណាអ្នកដឹកនាំ និងសមាជិកក្រុមជំនុំចាប់ផ្ដើមឃ្លាតចេញពីព្រះ នោះពួកគាត់នឹងលែងជួយអ្នកដែលមានតម្រូវការទៀតហើយ។

ក្រុមជំនុំនៅគ្រប់ទីកន្លែង មិនថាតូច ឬធំ សុទ្ធតែមានចំណែកក្នុងការបំពេញមហាបេសកកម្មរបស់ព្រះយេស៊ូវ (ម៉ាថាយ ២៨:១៨-២០)។ ប៉ុន្តែ នៅពេលដែលអ្នកជឿបណ្ដោយខ្លួនឲ្យធ្លាក់ ក៏ដូចជាចុះចូលចំពោះភាពត្រេកត្រអាលរបស់ខ្លួន នោះមានន័យថា ពួកគាត់ក៏បានអនុញ្ញាតឲ្យពន្លឺនៃដំណឹងល្អអន់ខ្សោយចុះដែរ។ ដោយសារសមាជិកមានភាពកម្សោយ នោះមានន័យថាព័ន្ធកិច្ចក្រុមជំនុំទៅកាន់អ្នកជិតខាងក៏នឹងធ្លាក់ចុះផងដែរ។

## ៣. ការមើលរូបភាព ឬក៏វីដេអូអាសអាភាសរារាំងព័ន្ធកិច្ច របស់ព្រះជាម្ចាស់*នៅលើផែនដី*ទាំងមូល

នៅពេលដែលសមាជិកក្រុមជំនុំមិនលន់តួបាបខ្លួន នោះមានន័យថា ព័ន្ធកិច្ចរួមគ្នានៅក្នុងក្រុមជំនុំនោះនឹងមានការអន់ថយដែរ។ បុរស និងស្ត្រីដែលធ្លាប់មានចិត្តឆេះឆួលក្នុងការលះបង់អ្វីៗទាំងអស់ចោល ដើម្បីចេញទៅផ្សាយដំណឹងល្អនៅលើលោកនេះ នឹងលែងចង់ចេញទៅទៀត ព្រោះពួកគាត់ចង់នៅផ្ទះ អស់កម្លាំង ហើយក៏បានលង់ក្នុងភាពងប់ងុលនៃលោកីយ៍នេះ។ អ្នកដឹកនាំដែលមានអំណោយទានក្នុងការលើកទឹកចិត្តក្រុមជំនុំឲ្យថ្វាយតង្វាយច្រើនជាងមុន ក៏ដូចជាផ្តោតទៅលើការចេញទៅផ្សាយដំណឹងល្អ នឹងមិនហើបមាត់ទៀតឡើយ ព្រោះពួកគាត់ខ្លាចមានគេដឹងពីអំពើបាបអាថ៌កំបាំងរបស់ខ្លួន។ សរុបសេចក្តីទៅ ក្រុមជំនុំទាំងមូលនឹងគិតតែពីខ្លួនឯង ដែលនោះជាហេតុដែលនឹងបណ្តាលឲ្យមនុស្សបាត់បង់មិនបានឮដំណឹងល្អសូម្បីតែពាក្យមួយម៉ាត់សោះ។ នៅពេលដែលយើងអនុញ្ញាតឲ្យការមើលរូបភាព ឬក៏វីដេអូអាសអាភាសមករារាំងមហាបេសកកម្មរបស់ព្រះជាម្ចាស់ នោះក៏មានន័យថានឹងមានមនុស្សជាច្រើនរងទុក្ខហើយ។

ទោះបើថានេះជាការសោកស្តាយដ៏ធំក៏ដោយ ក៏វាមិនទាន់ធំបំផុតនៅឡើយដែរ។ បញ្ហាដ៏ធំនោះគឺ៖ ព្រះជាម្ចាស់មិនបានទទួលសិរីល្អដែលទ្រង់ស័ក្តិសមនឹងទទួលបានពីគ្រប់ជាតិសាសន៍នៅលើផែនដីនេះ ដែលពួកគេគួរសរសើរតម្កើងទ្រង់។ ព្រះយេស៊ូវមិនបានទតឃើញក្រុមជំនុំរបស់ព្រះអង្គ ចេញទៅបង្កើតសិស្សតាមព្រះរាជបញ្ជារបស់ទ្រង់ដែលថា "ចូរទៅបង្កើតសិស្ស" នោះ

ទេ ផ្ទុយទៅវិញ ទ្រង់បែរជាទតឃើញពួកគេលង់ស្នេហ៍ដោយងប់ងុលនឹងសាច់ឈាមរបស់ខ្លួន ជាជាងព្រះយេស៊ូវដែល «បានទទួលសិទ្ធិអំណាចទាំងអស់ទាំងនៅស្ថានសួគ៌ និងនៅផែនដី» ទៅវិញ (ម៉ាថាយ ២៨:១៨ គគខ)។

## ព្រះយេស៊ូវមិនចាំបាច់ត្រូវការការអនុញ្ញាតពីនរណាម្នាក់ទេ

ចំពោះក្រុមជំនុំដែលកំពុងអន់ថយ ចូរកុំទាន់បាក់ទឹកចិត្តឡើយ ព្រោះនៅមានដំណឹងល្អនៅឡើយ៖ យើងមិនបំពេញព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ដោយពឹងលើកម្លាំងខ្លួនឯងទេ។ ក្រុមជំនុំកើតចេញមកពីព្រះគ្រីស្ទ ដឹកនាំដោយព្រះគ្រីស្ទ ហើយក៏មានការគាំទ្រដោយព្រះគ្រីស្ទដែរ។ ព្រះជាម្ចាស់មិនបានបោះបង់យើងចោលឲ្យនៅឯកាម្នាក់ឯងក្នុងការដោះស្រាយអំពើបាបរបស់ខ្លួនទេ។ តែផ្ទុយទៅវិញ ព្រះគម្ពីរបានបង្ហាញថា ព្រះគ្រីស្ទបានដេញតាមរាស្ត្ររបស់ទ្រង់ដោយគ្មានការរាថយឡើយ ហើយទ្រង់ក៏ពេញដោយព្រះគុណក្នុងការសង្គ្រោះពួកគេដែរ។

ព្រះយេស៊ូវមិនរង់ចាំការអនុញ្ញាតពីអ្នកណាទេ។ បើប្រៀបធៀបនឹងអ្នកផ្សព្វផ្សាយផលិតផលអ្វីមួយ គឺព្រះយេស៊ូវមិនខ្សោយដូចពួកគេទេ។ ដូច្នេះចូរកុំគិតថា យើងនឹងពិបាកក្នុងការទៅរកទ្រង់នោះឡើយ។ ព្រះយេស៊ូវបានត្រាស់ហៅបុរសសាមញ្ញៗឲ្យមកធ្វើជាសិស្សរបស់ទ្រង់។ ព្រះយេស៊ូវបានទៅព្យាបាលអស់អ្នកដែលឈឺ។ ព្រះយេស៊ូវបានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។ ព្រះយេស៊ូវបានយាងទៅសុគតលើឈើឆ្កាងជំនួសមនុស្សមានបាប ទ្រង់បានសង្គ្រោះពួកគេ ហើយក៏បាននាំពួកគេឲ្យមានការរួបរួមជាមួយនឹង

ទ្រង់ផ្ទាល់ផងដែរ។ យើងនឹងត្រូវបង់ថ្លៃយ៉ាងខ្ពស់ចំពោះការមើលរូបភាព ឬក៏វីដេអូអាសអាភាស។ តម្លៃខ្លះៗដែលយើងនឹងត្រូវខាតបង់នោះគឺ ខ្លួនឯង គ្រួសាររបស់យើង ក្រុមជំនុំរបស់យើង និងព័ន្ធកិច្ចរបស់យើង។ ប៉ុន្តែ ចូរចាំថា ព្រះគ្រីស្ទបានបង់ថ្លៃលោះសម្រាប់ការទាំងអស់នោះរួចហើយ ជាពិសេសចំពោះអស់អ្នកដែលព្រមទទួលជឿ ហើយដើរតាមទ្រង់។

ការយល់ដឹងរបស់យើងពីព្រះយេស៊ូវមានអត្ថប្រយោជន៍ណាស់ទាក់ទងនឹងការតយុទ្ធចំពោះការមើលរូបភាព និងវីដេអូអាសអាភាស។ ព្រះយេស៊ូវជ្រាបថា យើងជាអ្នកណា ទ្រង់ជ្រាបថា យើងមិនគួរធ្វើនូវអ្វីដែលយើងមិនគួរធ្វើ ប៉ុន្តែទ្រង់នឹងមិនបោះបង់យើងចោលឡើយ។ ព្រះអង្គនឹងចេញទៅរកចៀមដែលបាត់បង់ សូម្បីតែមួយក៏ព្រះអង្គនឹងចេញទៅដែរ (លូកា ១៥:១-៧)។ ព្រះអង្គប្រទានកម្លាំងដល់យើង ទោះបីជានៅពេលដែលទ្រង់ស្តីបន្ទោសយើង ក៏ព្រះអង្គនៅតែស្តារយើងឡើងវិញដែរ។ អារក្សសាតាំងរករឿងយើង ហើយព្យាយាមបំផ្លាញយើង ប៉ុន្តែ ព្រះយេស៊ូវវិញ ទ្រង់អធិស្ឋានជំនួសយើង ហើយប្រទានកម្លាំងដល់យើង ដើម្បីឲ្យយើងអាចយកជ័យជម្នះតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ (រ៉ូម ៨:៣៧; ហេព្រើរ ៧:២៥; វិវរណៈ ១២:១០-១២)។ ទោះបីជាព័ន្ធកិច្ចមិនសូវសកម្មក៏ដោយ ក៏ព្រះយេស៊ូវនឹងធ្វើឲ្យវារស់រវើកឡើងវិញបានដែរ។

## ខ្លាំងជាងការមើលរូបភាព ឬក៏វីដេអូអាសអាភាសទៅទៀត

តម្រូវការដ៏ធំបំផុតសម្រាប់គ្រីស្ទបរិស័ទក្នុងការតយុទ្ធជាមួយការមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺមិនមែនជាអាវុធថ្មី ឬក៏វិធីថ្មីនោះទេ ប៉ុន្តែ

គឺយើងត្រូវការព្រះគ្រីស្ទផ្ទាល់! ព្រះយេស៊ូវគឺជាចម្លើយចំពោះអ្នកជឿណាដែលខ្សោយខាងឯវិញ្ញាណដែលពួកគាត់ខ្សោយរហូតដើរទៅមុខលែងរួច។ ព្រះយេស៊ូវនឹងដាស់អ្នកដែលកំពុងគេងឲ្យភ្ញាក់ឡើង ហើយប្រទានកម្លាំងដល់ពួកអ្នកខ្សោយ។ ព្រះយេស៊ូវ គឺជាចម្លើយចំពោះក្រុមជំនុំដែលមិនសូវមានការរស់រវើក។ ព្រះអង្គនឹងប្រទានកម្លាំងដល់ដៃអ្នកដឹកនាំ និងសមាជិកក្រុមជំនុំ ដោយជួយពួកគេឲ្យមានការយល់ដឹងអំពីព្រះរាជបុត្រារបស់ព្រះជាម្ចាស់ជាថ្មី និងជួយពួកគេឲ្យស្តាប់បង្គាប់ព្រះវរបិតាដោយបំពេញព័ន្ធកិច្ចដែលទ្រង់បានប្រទានដល់ពួកគេ (យ៉ូហាន ៦:៣៨)។ ព្រះយេស៊ូវនឹងស្តារក្តីសង្ឃឹម ព្រមទាំងគោលបំណងឡើងវិញចំពោះអស់អ្នកដែលមិនសូវមានភាពឆេះឆួលក្នុងការបម្រើព័ន្ធកិច្ចរបស់ទ្រង់។

ប្រសិនបើក្រុមជំនុំណាមួយអនុញ្ញាតឲ្យសមាជិកមើលរូបភាព ឬក៏វីដេអូអាសអាភាស ការអនុញ្ញាតបែបនោះនឹងធ្វើឲ្យក្រុមជំនុំកាន់តែខ្សោយទៅៗ។ តែចូរសរសើរព្រះជាម្ចាស់ ព្រោះព្រះយេស៊ូវទ្រង់ខ្លាំងជាងការមើលរូបភាព និងវីដេអូអាសអាភាសទៅទៀត។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Owen Strachan
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង ប៉ូរ៉ា, លោក ជួប ប៊ុនហាក់. លោក ទេព រ៉ូ និង លោក អ៊ុន ជ័យរិទ្ធ
ដកស្រង់ខ្លះៗចេញពី http://www.desiringgod.org/articles/the-high-cost-of-free-porn ដោយមានការអនុញ្ញាត។
លោកអ្នកអាចអានអត្ថបទនេះនៅលើគេហទំព័រ http://plovpit.com/high-cost-of-porn/

# ៣

# ការកុហក ៥យ៉ាងចេញពីការមើលរូបមិនគប្បី

ពេលដែលខ្ញុំសរសេរពីកំណត់ហេតុទាក់ទងនឹងបញ្ហានៃការមើលរូបភាព និងវីដេអូអាសអាភាស វាបានបង្ហាញឲ្យឃើញថា ការមើលរូបភាព និងរឿងដូចនេះកំពុងតែរីកដុះដាលយ៉ាងខ្លាំងនៅក្នុងពិភពលោកយើងនេះ។ ក្រោយមកកំណត់ហេតុនេះ ក៏បានក្លាយទៅជាសៀវភៅមួយដែលមានចំណងជើងថា *Sexual Detox* ដែលសៀវភៅនេះមានរៀបរាប់ពីអំពើបាបទាំងនោះបានក្លាយទៅជាស្រមោលអតីតកាលដក់ជាប់នៅក្នុងជីវិតមនុស្សជាច្រើន។ មានមនុស្សតិចណាស់ដែលបានដឹងថា អំពើបាបនេះមានពោរពេញទៅដោយគ្រោះថ្នាក់ និងភាពសាហាវឃោរឃៅ។ កាលពី១០ឆ្នាំមុន មានមនុស្សភាគតិចណាស់ដែលយល់ពីគ្រោះថ្នាក់នៃការមើលរូបភាព និងវីដេអូអាសអាភាស

ប៉ុន្តែឥឡូវនេះ យើងទើបនឹងចាប់ផ្តើមយល់អំពីគ្រោះថ្នាក់ដ៏កាចសាហាវមួយនេះ។ នៅពេលនេះយើងបានដឹងថា មានក្មេងប្រុសស្រីជំទង់ជាច្រើនបានចាប់ផ្តើមប្រឡូកមើលរូបភាព ឬវីដេអូអាសអាភាស ហើយពួកគេក៏កំពុងតែបន្តនៅមើល តែក៏មានអ្នកខ្លះកំពុងតយុទ្ធ ហើយខ្លះទៀតក៏កំពុងញៀននឹងការមើលរូបភាពទាំងនោះជាដដែលៗ។ នេះហើយជាមូលហេតុដែលខ្ញុំត្រឡប់មកសរសេរខ្លឹមសារដែលទាក់ទងនឹងប្រធានបទនេះ ដោយរំពឹងថានឹងបានផ្តល់ក្តីសង្ឃឹមដល់ពួកគេ។ ខ្លឹមសារក្នុងឯកសារនេះ យើងខ្ញុំមានបំណងចង់លើកឡើងអំពីការកុហកដ៏អាក្រក់មួយចំនួនដែលចេញមកពីការមើលរូបភាព ឬវីដេអូអាសអាភាសដល់លោកអ្នកដូចតទៅនេះ៖

## ១. វាមិនមែនជារឿងធំដុំទេ

ការកុហកដ៏ចម្បងមួយដែលលោកអ្នកនឹងជួបប្រទះ នៅពេលដែលលោកអ្នកប្រឈមមុខទៅនឹងការល្បួងទាក់ទងនឹងការមើលរូបភាពមិនគប្បីដែលវានឹងធ្វើឲ្យលោកអ្នកជឿថា៖ *នោះមិនមែនជារឿងធំដុំនោះទេ។* ប្រសិនបើមនុស្សគ្រប់គ្នាកំពុងតែមើលរឿងដូចនេះ នោះវាមិនមែនជាអំពើបាបធ្ងន់ធ្ងរនោះទេ។ តើនោះជាការពិតទេ?

ព្រះគម្ពីរបានលើកឡើងនូវរឿងរ៉ាវផ្ទុយពីគំនិតបែបនោះ។ សាវ័ក ប៉ុលបានលើកឡើងថា «ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យ ឲ្យអ្នករាល់គ្នាបានញែកជាបរិសុទ្ធ ដើម្បីឲ្យបានចៀសពីសេចក្តីកំផិតចេញ...ដ្បិតព្រះមិនបានហៅយើងរាល់គ្នា មកក្នុងសេចក្តីស្មោកគ្រោកទេ គឺមកក្នុងសេចក្តីបរិសុទ្ធវិញ»

(១ថែស្សាឡូនីច៤:៣, ៧)។ ព្រះជាម្ចាស់បានត្រាស់ហៅគ្រីស្ទបរិស័ទឲ្យរស់-នៅប្រកបដោយភាពបរិសុទ្ធខាងផ្លូវភេទ។ សាវ័ក ប៉ុល បានបន្តលើកឡើងនូវចំណុចដ៏គួរឲ្យរន្ធត់មួយទៀតថា "អ្នកណាដែលមិនព្រមទទួល នោះមិន-មែនបោះបង់ចោលមនុស្ស ឈ្មោះថាបោះបង់ចោលព្រះវិញ ដែលទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់មកយើង" (១ថែស្សាឡូនីច ៤:៨)។ នៅពេលដែលលោកអ្នកមើលរូបភាព ឬវីដេអូអាសអាភាស នោះមានន័យថាលោកអ្នកកំពុងតែប្រព្រឹត្តអំពើបាបទាស់នឹងអំណាចព្រះចេស្ដា និងព្រះវត្ត-មាននៃព្រះវិញ្ញាណបរិសុទ្ធដែលស្ថិតនៅក្នុងជីវិតរបស់លោកអ្នកហើយ។ ព្រះអង្គកំពុងតែប្រាប់លោកអ្នកមិនឲ្យប្រព្រឹត្តបាប ប៉ុន្តែលោកអ្នកនៅតែបន្តល្មើសទាស់នឹងព្រះហឫទ័យទ្រង់ដដែល។

ក្នុងនាមលោកអ្នកជាគ្រីស្ទបរិស័ទ គឺលោកអ្នកបានប្រកាន់ជំនឿលើព្រះគ្រីស្ទ ព្រមទាំងបានទទួលព្រះវិញ្ញាណបរិសុទ្ធដែលកំពុងរស់នៅក្នុងជីវិតរបស់លោកអ្នកផងដែរ។ ព្រះវិញ្ញាណបរិសុទ្ធនេះហើយ ជាអង្គដែលកំពុងប្រាប់លោកអ្នកកុំឲ្យបន្តប្រព្រឹត្តអំពើបាបទៀត ហើយព្រះអង្គក៏បានអះអាងដល់លោកអ្នកដែរថា ទ្រង់នឹងជួយលោកអ្នកឲ្យចេះរស់នៅក្នុងរបៀបមួយដែលត្រឹមត្រូវ។ ការដែលលោកអ្នកនៅតែបន្តប្រព្រឹត្តអំពើបាបនោះជាដដែលៗនោះជាការខុសឆ្គងខ្លាំងណាស់។ រាល់ពេលដែលលោកអ្នកប្រព្រឹត្តអំពើបាបបែបនោះ មានន័យថាលោកអ្នកកំពុងតែបន្តប្រព្រឹត្តអំពើបាបយ៉ាងសកម្មដែលវាជំទាស់នឹងព្រះវត្តមានរបស់ព្រះជាម្ចាស់ដែលកំពុងគង់នៅក្នុងលោកអ្នក។ នេះមិនមែនជារឿងតូចតាចនោះឡើយ។

## ២. ការមើលរូបភាព ឬវីដេអូអាសអាភាសជះឥទ្ធិពលលើខ្ញុំតែម្នាក់ប៉ុណ្ណោះ

ការកុហកទីពីរគឺ ការគិតថាការមើលរូបភាព ឬវីដេអូអាសអាភាស*គ្រាន់តែជះឥទ្ធិពលលើខ្លួនខ្ញុំតែម្នាក់ប៉ុណ្ណោះ។* ការមើលរូបភាពពុំគប្បីធ្វើឲ្យលោក-អ្នកជឿថា ការមើលនេះគឺគ្រាន់តែជាបញ្ហាផ្ទាល់ខ្លួនរបស់លោកអ្នក តែពុំមែនជាបញ្ហារបស់អ្នកដទៃឡើយ។ ទោះបើការនេះពិតជាមានគ្រោះថ្នាក់មែន ក៏លោកអ្នកនៅតែហ៊ានបង្ខំខ្លួនឲ្យគិតថា គ្រោះថ្នាក់នេះបានកើតឡើងមកលើលោកអ្នកតែម្នាក់ឯងប៉ុណ្ណោះ។ បើលោកអ្នកកំពុងតែប្រឈមមុខនឹងការល្បួងឲ្យជឿលើសេចក្ដីកុហកបែបនេះ នោះខ្ញុំចង់លើកទឹកចិត្តលោកអ្នកឲ្យចំណាយពេលខ្លះ ដើម្បីគិតអំពីគ្រោះថ្នាក់ដែលបណ្ដាលមកពីការមើលរូប-ភាព ឬក៏វីដេអូអាសអាភាសទាំងនេះដូចតទៅ៖

*វាគ្រោះថ្នាក់ដល់ព្រលឹងវិញ្ញាណរបស់លោកអ្នក។* ប្រសិនបើលោកអ្នកនៅតែបន្តបណ្ដោយខ្លួនឲ្យញៀននឹងការមើលរូបភាព ឬវីដេអូអាសអាភាស ហើយពុំមានចិត្តចង់សម្លាប់អំពើបាបហ្នឹងចោល នោះមានន័យថា លោកអ្នកមានហេតុផលសួរខ្លួនឯងថា តើព្រលឹងរបស់ខ្ញុំបានទទួលការសង្គ្រោះហើយឬនៅ? ប្រសិនបើលោកអ្នកពុំមានវិប្បដិសារីនឹងអំពើបាប មិនមានចិត្តប្រា-ថ្នាចង់យកឈ្នះលើអំពើបាបនោះ ហើយនៅតែបន្តជ្រើសរើសនូវការប្រព្រឹត្តអំពើបាបនេះម្ដងហើយម្ដងទៀត ដោយមិនមានចិត្តចង់បានព្រះយេស៊ូវដែលជាព្រះអង្គសង្គ្រោះរបស់លោកអ្នក នោះលោកអ្នកគួរតែសួរខ្លួនឯងថា៖ តើខ្ញុំស្រឡាញ់រូបភាព និងវីដេអូអាសអាភាសទាំងនោះដល់កម្រិតដែលអាចឲ្យខ្ញុំ

ហ៊ានធ្លាក់នរកដោយសារវាមែនឬ? ដើម្បីជាប្រយោជន៍ដល់ព្រលឹងវិញ្ញាណរបស់លោកអ្នក ចូរឈប់មើលវាទៅ!

*វាគ្រោះថ្នាក់មួយដល់អ្នកជិតខាងរបស់លោកអ្នក។* ព្រះយេស៊ូវបានប្រាប់ឲ្យយើងស្រឡាញ់អ្នកជិតខាងឲ្យដូចខ្លួនយើង។ មនុស្សនៅក្នុងរូបភាពដែលលោកអ្នកកំពុងមើល គឺសុទ្ធសឹងតែជាអ្នកជិតខាងរបស់លោកអ្នក។ ពួកគាត់ក៏ជាមនុស្សដែលព្រះជាម្ចាស់បានបង្កើតមកក្នុងរូបអង្គទ្រង់សម្រាប់ថ្វាយសិរី-ល្អដល់ទ្រង់ដែរ។ តើការដែលលោកអ្នកមើលនូវអ្វីដែលពួកគាត់កំពុងធ្វើ បានបង្ហាញថា លោកអ្នកស្រឡាញ់ពួកគាត់ដែរឬទេ? ចម្លើយគឺ ទេ! នៅពេលដែលលោកអ្នកបណ្ដោយខ្លួនទៅមើលរូបភាពដែលពុំគប្បីទាំងនោះ នោះមានន័យថា លោកអ្នកបានជ្រើសរើសចូលរួមប្រព្រឹត្តអំពើបាបខាងផ្លូវភេទក៏ដូចជាបានអនុញ្ញាតឲ្យអ្នកដែលគេថតរូប ឬវីដេអូអាសអាភាសទាំងនោះប្រព្រឹត្តអំពើបាប ដើម្បីជាប្រយោជន៍ដល់ភាពស្រើបស្រាលរបស់ខ្លួនអ្នកផងនោះ។ ដូចនេះ ដើម្បីជាប្រយោជន៍ដល់អ្នកជិតខាង ចូរឈប់មើលវាទៅ!

*វាគ្រោះថ្នាក់ដល់ក្រុមជំនុំរបស់លោកអ្នក។* មានបុរសជាច្រើនដែលមានលក្ខណសម្បត្តិស័ក្ដិសមធ្វើជាគ្រូគង្វាល ឬជាអ្នកដឹកនាំក្នុងក្រុមជំនុំ ប៉ុន្ដែគួរឲ្យសោកស្ដាយណាស់ដែលពួកគាត់បែរជាជ្រើសរើសយកការស្រឡាញ់រូប-ភាព ឬវីដេអូអាសអាភាសជាជាងស្រឡាញ់ក្រុមជំនុំទៅវិញ។ មិនតែប៉ុណ្ណោះក៏មានស្ត្រីជាច្រើននាក់ដែរ ដែលស័ក្ដិសមនឹងធ្វើជាអ្នកដឹកនាំក្នុងព័ន្ធកិច្ចស្ត្រី ប៉ុន្ដែពួកគាត់មិនអាចធ្វើបាន ហើយក៏ពុំព្រមធ្វើជាអ្នកដឹកនាំដែរ ដោយសារពួកគាត់ពុំមានសិទ្ធិតទៅទៀតឡើយ។ នេះមកពីពួកគាត់បានជ្រើសរើសដើរក្នុង

គន្លងនៃការបំពេញភាពស្រើបស្រាលក្នុងកាមតណ្ហារបស់ខ្លួន។ ដូច្នេះដើម្បីជាប្រយោជន៍ដល់ក្រុមជំនុំរបស់លោកអ្នក ចូរឈប់មើលវាទៅ!

*វាគ្រោះថ្នាក់ដល់សុភមង្គលនៃក្រុមគ្រួសាររបស់លោកអ្នក។* បុរសជាច្រើនកំពុងតែបំផ្លាញសុភមង្គលគ្រួសាររបស់ខ្លួន ដោយសារគាត់ចង់បាននូវភាពរីករាយដែលមិនត្រឹមត្រូវ។ មួយវិញទៀតសោត ក៏មានមនុស្សស្រីជាច្រើនដែលកំពុងតែបដិសេធនឹងការយកចិត្តទុកដាក់ពីប្តីរបស់ខ្លួន ដោយសារពួកគាត់ចង់អាន ឬមើលនូវអ្វីដែលពុំគប្បី។ ក្មេងៗក៏កំពុងតែចាប់ផ្តើមមើលវីដេអូ ឬរូបភាពអាសអាភាសដែរ ដោយសារតែឪពុកម្តាយរបស់ពួកគាត់បានបន្សល់ទុកនូវអ្វីដែលពុំគួរគប្បីដល់ពួកគេ។ ឪពុកជាច្រើនកំពុងតែអញ្ជើញអារក្សសាតាំងឲ្យមកគ្រងរាជ្យក្នុងផ្ទះរបស់ខ្លួន ពីព្រោះពួកគាត់បានប្រព្រឹត្តនូវអ្វីដែលអារក្សសាតាំងពេញចិត្ត ជាជាងធ្វើតាមព្រះហឫទ័យដែលទ្រង់ហាមមិនឲ្យធ្វើ។ ដូច្នេះដើម្បីសុភមង្គលក្នុងក្រុមគ្រួសាររបស់លោកអ្នក ចូរឈប់មើលវាទៅ!

*វាគ្រោះថ្នាក់ដល់សេចក្តីសង្គ្រោះរបស់លោកអ្នក។* ជាការពិតណាស់ នេះគឺជាគ្រោះថ្នាក់ដ៏ធំបំផុតក្នុងចំណោមគ្រោះថ្នាក់ឯទៀតៗ។ ក្នុងនាមលោកអ្នកជាគ្រីស្ទបរិស័ទ បើលោកអ្នកនៅតែបន្តមើលរូបភាព ឬក៏រឿងអាសអាភាសនោះមានន័យថា លោកអ្នកទទួលស្គាល់ថា តម្លៃនៃការអត់ទោសដោយការសុគតរបស់ព្រះគ្រីស្ទគ្មានសារៈសំខាន់អ្វីនោះទេ។ ព្រះយេស៊ូវបានរងទុក្ខហើយសុគត ដើម្បីលោះបាបរបស់លោកអ្នក។ ដូច្នេះ ក្នុងនាមជាគ្រីស្ទបរិស័ទមួយរូប ហេតុអ្វីក៏លោកអ្នកបែរជាលេងសើច ហើយប្រឡូកជាមួយនឹងអំពើបាប ព្រមទាំងរាប់វាថា មិនមែនជាបញ្ហាធំដុំដូច្នោះ? ហេតុអ្វីបានជា

លោកអ្នកនៅតែបន្តឱបក្រសោបអំពើបាបទាំងនោះទៀត? ដូច្នេះដើម្បីសិរី-ល្អរបស់ព្រះជាម្ចាស់ ចូរឈប់មើលវាទៅ!

## ៣. នេះជារឿងអាថ៌កំបាំងរបស់ខ្ញុំ

ការកុហកទី៣ *ការមើលរូបភាព ឬវីដេអូអាសអាភាសគ្រាន់តែជារឿងអាថ៌កំ-បាំងសម្រាប់តែខ្ញុំម្នាក់ឯងប៉ុណ្ណោះ។* លោកអ្នកក៏ប្រហែលជាប្រឈមមុខនឹងសេចក្តីល្បួង ដោយលោកអ្នកចង់ជឿថា អ្វីៗដែលលោកអ្នកបានធ្វើនៅក្នុងបន្ទប់ គឺគ្រាន់តែជារឿងផ្ទាល់ខ្លួនរបស់លោកអ្នក ដោយវាពុំមែនជារឿងរបស់អ្នកដទៃ។ ការកុហកដែលចេញមកពីការមើលរូបភាពពុំគប្បីបានលើកឡើងថា ទាំងនេះគឺជារឿងអាថ៌កំបាំងរបស់លោកអ្នក ដែលគ្មាននរណាម្នាក់ដឹងក្រៅពីលោកអ្នកឡើយ។ ក៏ប៉ុន្តែ តើលោកអ្នកចាំទេថា អំពើបាបដែលលោក-អ្នកបានប្រព្រឹត្តតែងតែតាមលោកអ្នកទាន់ (ជនគណនា ៣២:២៣)? អំពើបាបតែងតែក្បត់យើងបែបហ្នឹងជានិច្ច។ អំពើបាបតែងតែចូលចិត្តបង្ខំលោក-អ្នកឲ្យជឿថា ខ្លួនរបស់លោកអ្នកផ្ទាល់ គឺជាអ្នកដែលគ្រប់គ្រងលើគ្រប់កាលៈ-ទេសៈទាំងអស់ ជាមេ ហើយជាអ្នកដែលអាចសម្រេចថានឹងបញ្ឈប់នូវការប្រព្រឹត្តបាបដែលខ្លួនកំពុងធ្វើ ក៏ដូចជាបោះបង់អំពើបាបនោះចោលបាន។ ទោះជាយ៉ាងណាក៏ដោយ ក៏ការនោះមិនមែនជាលក្ខណសម្បត្តិនៃអំពើបាបឡើយ។ នៅពេលដែលខ្ញុំយកអំពើបាបមកប្រៀបធៀបថាជាបុគ្គលណាម្នាក់ (អំពើបាប=បុគ្គល) ខ្ញុំបានឃើញថា អំពើបាបគឺជាតួអង្គដ៏អាក្រក់បំផុតដែលចង់បំផ្លាញរូបកាយខ្ញុំ ព្រលឹងខ្ញុំ ចិត្តគំនិតខ្ញុំ ទំនាក់ទំនងខ្ញុំ ព្រមទាំង

កេរ្តិ៍ឈ្មោះរបស់ខ្ញុំ។ សរុបមក អំពើបាបចង់បំផ្លាញគ្រប់ទាំងកិច្ចការក្នុងជីវិតរបស់លោកអ្នក។ អំពើបាបបានក្លែងខ្លួនធ្វើជានុយ ដើម្បីមកល្បួងលោកអ្នក ហើយចង់ឲ្យលោកអ្នកស៊ីនុយនោះ បន្ទាប់មកវានឹងបំផ្លាញលោកអ្នកចោលទាំងស្រុង (យ៉ាកុប ១)។

អំពើបាបរបស់លោកអ្នកនឹងដើរទាន់លោកអ្នក (ជនគណនា ៣២:២៣)។ វាចង់ទាញនាំលោកអ្នកឲ្យទៅប្រព្រឹត្តតាមវា និងឲ្យលោកអ្នកគិតថា អ្នកជាម្ចាស់លើខ្លួនឯង មានសន្តិភាព មិនឲ្យលោកអ្នករវីរវល់នឹងអ្វីទាំងអស់ តែបន្ទាប់មក វានឹងត្របាក់លេបលោកអ្នក រួចខ្ជាក់ចេញមកវិញ (១ពេត្រុស ៥:៨)។ តើលោកអ្នកមិនបានឃើញពីចំណុចទាំងនោះទេឬអី? អំពើបាបចង់ឲ្យលោកអ្នកគិតថា ការមើលរូបភាព ឬវីដេអូអាសអាភាស គ្រាន់តែជារឿងអាថ៌កំបាំងផ្ទាល់ខ្លួន ហើយក៏ពុំមានគ្រោះថ្នាក់អ្វីដែរ។ ក៏ប៉ុន្តែ សូមចងចាំថា មិនយូរមិនឆាប់នឹងមាននរណាម្នាក់មកតាមទាន់លោកអ្នក នៅពេលដែលលោកអ្នកកំពុងតែមើលរូបភាពនោះ ហើយក៏នឹងមាននរណាម្នាក់ទៀតមើលឃើញពីប្រវត្តិគេហទំព័រដែលលោកអ្នកបានបើកមើល (website search history) ហើយក៏នឹងមាននរណាម្នាក់ឃើញអំពីរបៀប និងទីកន្លែងដែលលោកអ្នកចាយលុយផងដែរ។ អំពើបាបចង់បង្ហាញអំពីអ្វីៗដែលលោកអ្នកបានធ្វើឲ្យអ្នកដទៃឃើញ ហើយចង់បំបាក់មុខលោកអ្នក ព្រមទាំងចង់ប្រើការជំពប់ដួលនោះ ដើម្បីបន្ថោកតម្លៃនៃដំណឹងល្អផងដែរ។

## ៤. អំពើបាបនេះនឹងធ្វើឲ្យខ្ញុំស្កប់ស្កល់

ការកុហកទី៤ *ការមើលរូបភាព ឬវីដេអូអាសអាភាសនឹងធ្វើឲ្យលោក-អ្នកស្កប់ស្កល់។* លោកអ្នកបានស្គាល់ពីអារម្មណ៍នេះហើយថា ពេលដែលលោកអ្នកសម្រេបខ្លួនដោយជឿលើសេចក្តីកុហកដែលថា បើលោកអ្នកប្រព្រឹត្តបាប ពេលនោះឯងលោកអ្នកនឹងមានភាពស្កប់ស្កល់យ៉ាងពិតប្រាកដ តែបើលោកអ្នកមិនព្រមធ្វើតាមអំពើបាបនោះទេ លោកអ្នកក៏មិនអាចមានភាពស្កប់ស្កល់បានដែរ។ របៀបមួយដែលអាចឲ្យលោកអ្នកអរសប្បាយឥឡូវនេះបាន របៀបមួយដែលអាចឲ្យលោកអ្នកស្កប់ស្កល់បាន របៀបមួយដែលអាចឲ្យលោកអ្នកគេងលក់ស្រួលបាននៅពេលយប់នេះ នោះគឺលោក-អ្នកត្រូវតែប្រព្រឹត្តអំពើបាប។

អំពើបាបតែងតែសន្យាថា វានឹងនាំឲ្យលោកអ្នកមានភាពស្កប់ស្កល់ ប៉ុន្តែវាមិនដែលបំពេញក្តីសន្យារបស់វាឲ្យបានលើសពីពីរបីវិនាទីនោះឡើយ។ ជាទីបញ្ចប់ វាតែងតែសន្យាលើសពីអ្វីដែលវាអាចបំពេញបាន ជាពិសេសចំពោះអំពើបាបដែលទាក់ទងនឹងផ្លូវភេទ។ នៅពេលដែលលោកអ្នកធ្លាក់ចូលទៅក្នុងសេចក្តីល្បួងបែបនេះ នោះលោកអ្នកនឹងកត់សម្គាល់ឃើញថាភាពស្កប់ស្កល់មានតែមួយភ្លែតប៉ុណ្ណោះ ដែលវាមិនមែនជាភាពស្កប់ស្កល់ដ៏ពិតដល់ព្រលឹងវិញ្ញាណរបស់លោកអ្នកឡើយ។ ព្រះជាម្ចាស់បានសន្យាថា សេចក្តីអំណរដ៏ពិតប្រាកដ នឹងអាចកើតមានឡើងតាមរយៈការស្តាប់-បង្គាប់ទ្រង់ មិនមែនការជំទាស់នឹងទ្រង់ឡើយ។ ទ្រង់មានព្រះហឫទ័យចង់បង្ហាញការនោះដល់លោកអ្នក ក៏ប៉ុន្តែលុះត្រាតែលោកអ្នកអនុញ្ញាតឲ្យទ្រង់

បង្ហាញការនោះ នោះទើបព្រះអង្គអាចធ្វើការបាន។ មានតែការស្តាប់បង្គាប់ទ្រង់មួយតែប៉ុណ្ណោះដែលអាចនាំលោកអ្នកឲ្យស្គាល់ពីព្រះពរនៃការស្តាប់-បង្គាប់នេះបាន។ បើលោកអ្នកនៅតែបន្តចុះចូលនឹងអំពើបាបជារៀងរាល់ថ្ងៃ នោះលោកអ្នកពិតជាមិនអាចស្គាល់នូវព្រះពរដែលព្រះជាម្ចាស់បានរៀប-ចំទុកសម្រាប់អស់អ្នកដែលបានស្តាប់បង្គាប់ទ្រង់ឡើយ។ ផ្ទុយពីការសន្យាដែលធ្វើឲ្យលោកអ្នកបានស្កប់ស្កល់ គឺសេចក្តីហិនវិនាស។ ព្រះវរបិតាទ្រង់បានសន្យាថា ទ្រង់នឹងប្រទានភាពស្កប់ស្កល់ ហើយលើសពីនោះទៅទៀតទ្រង់បានប្រទាននូវអ្វីដែលយើងបានសុំ ហើយគិតមិនដល់។ ចូរទទួលជឿសេចក្តីសន្យារបស់ទ្រង់ចុះ!

## ៥. ពុំមាននរណាម្នាក់អាចសង្គ្រោះខ្ញុំបានឡើយ

នេះគឺជាការកុហកទី៥ លោកអ្នកបានគិតថាមិនមាននរណាម្នាក់អាចសង្គ្រោះខ្ញុំឲ្យរួចពីការមើលរូបភាព ឬវីដេអូអាសអាភាស។ ការកុហកដ៏ចម្បងទាក់ទងនឹងការមើលរូបភាពពុំគប្បី៖ គឺជាការដែលយើងជឿថា ការមើលរូប-ភាព ឬក៏វីដេអូអាសអាភាសជាចៅហ្វាយលើជីវិតរបស់លោកអ្នក ហើយគ្មាននរណាម្នាក់អាចជួយរំដោះលោកអ្នកបានឡើយ ពោលគឺលោកអ្នកគ្មានក្តីសង្ឃឹម ទាំងចិត្ត និងគំនិតរបស់ខ្លួន។ វាប្រហែលជាកំពុងតែខ្សឹបខ្សៀវដាក់ត្រ-ចៀកលោកអ្នកថា ឯងបានធ្វើបាបនេះច្រើនដងពេកហើយ រហូតដល់ក្លាយជាទម្លាប់ដែលឯងគ្មានផ្លូវណាអាចនឹងកែខ្លួនបានទេ។

យ៉ាងណាមិញ ការមានគំនិតបែបនេះ គឺមិនមែនជារឿងដែលត្រឹមត្រូវ និង

សមហេតុផលឡើយ។ តាមពិតវាគឺជាការកុហកដែលចេញពីមាត់អារក្សសា-តាំងផ្ទាល់តែម្តង ហើយក៏ជាការបដិសេធដំណឹងល្អចោលទាំងស្រុងដែរ។ ព្រះយេស៊ូវបានមានបន្ទូលថា «អ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ដ្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ» (១កូរិនថូស ៦:១៩-២០)។ ព្រះអង្គបានយកព្រះលោហិតទ្រង់ ដើម្បីទិញលោកអ្នក ដែលនេះមានន័យថា ព្រះអង្គជាម្ចាស់លើលោកអ្នក ហើយលោកអ្នកគឺជាកម្មសិទ្ធិរបស់ទ្រង់។ ការមើលរូបភាព ឬក៏វីដេអូអាសអាភាសមិនមែនជាម្ចាស់លើជីវិតលោកអ្នកទេ តែព្រះយេស៊ូវទេដែលជាម្ចាស់លើលោកអ្នក! ព្រះអង្គបាន «ធ្វើទាំងអស់ឡើងជាថ្មី» វិញ (វិវរណៈ ២១:៥)។ នេះមិនមែនមានតែរុក្ខជាតិ ចក្រវាល ឬផែនដីថ្មីនោះឡើយ ប៉ុន្តែគឺលោកអ្នកនេះហើយដែលព្រះជាម្ចាស់ទ្រង់បានច្នៃជាថ្មី។ ទ្រង់កំពុងតែច្នៃលោកអ្នកឡើងជាថ្មីវិញ ដែលនេះមានន័យថា ព្រះអង្គកំពុងតែបំផ្លាញនូវគ្រប់ទាំងអំពើបាបដែលមានក្នុងលោកអ្នក ហើយទ្រង់ក៏កំពុងត្រាស់ហៅលោកអ្នកឲ្យមានជីវិតថ្មី ឲ្យទទួលបាននូវភាពបរិសុទ្ធ និងបានរាប់លោកអ្នកជាសុចរិតផងដែរ។ អំណាចព្រះចេស្តារបស់ព្រះយេស៊ូវធំជាងអំណាចនៃការមើលនូវរូបភាព ឬវីដេអូអាសអាភាសទៅទៀត ពោលគឺធំជាងអ្វីដែលលោកអ្នកអាចពណ៌នាបាន។

ពិតជាមានអ្នកដែលអាចជួយលោកអ្នកបាន! គ្មានអំពើបាបណាមួយដែលព្រះលោហិតរបស់ព្រះយេស៊ូវលុបលាងមិនបានឡើយ ហើយក៏គ្មានអំពើបាបណាមួយដែលលោកអ្នកប្រព្រឹត្តច្រើនដងពេក រហូតដល់លោក-អ្នកមិនអាចផ្តាច់វាចោលបាននោះដែរ។ មិនមានអំពើបាបណាមួយធំហួស

ពេកដែលព្រះយេស៊ូវមិនអាចអត់ទោសឲ្យបានដែរនោះឡើយ។ ដូច្នេះ ចូរកុំអស់សង្ឃឹមឡើយ! កុំអនុញ្ញាតឲ្យខ្លួនឯងគិតថា គ្មាននរណាម្នាក់អាចជួយខ្ញុំបានឡើយ។ ក្តីសង្ឃឹមដ៏ធំបំផុតរបស់លោកអ្នក គឺដំណឹងល្អរបស់ព្រះគ្រីស្ទ!

បើលោកអ្នកកំពុងជឿទុកចិត្តលើព្រះគ្រីស្ទ កំពុងសង្វាតចាប់យកក្តីសន្យារបស់ព្រះជាម្ចាស់ និងកំពុងជឿលើដំណឹងល្អ នោះមានន័យថា លោកអ្នកនឹងមិនជ្រើសរើសមើលរូបភាព ឬវីដេអូអាសអាភាសម្តងទៀតឡើយ។ ប្រសិនបើលោកអ្នកអនុញ្ញាតឲ្យព្រះជាម្ចាស់ជួយ នោះព្រះអង្គនឹងជួយលោកអ្នកដោយអំណរ ដើម្បីមិនឲ្យលោកអ្នកបណ្តោយខ្លួនទៅមើលរូបភាព ឬវីដេអូអាសអាភាសតទៅទៀតឡើយ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Tim Challies
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក អ៊ុន ជ័យរិទ្ធ, លោក ជួប ប៊ុនហាក់, លោក ទេព រ៉ូ និងកញ្ញា ថន ស្ថាពរ
ដកស្រង់ខ្លះៗចេញពី https://www.challies.com/articles/5-ways-porn-lies-to-you ដោយមានការអនុញ្ញាត។
លោកអ្នកអាចអានអត្ថបទនេះនៅលើគេហទំព័រ https://plovpit.com/porn-lies/

# ៤

# ភាពបរិសុទ្ធ បែបវិជ្ជមាន

ក្នុងយុគសម័យដែលយើងកំពុងរស់នៅសព្វថ្ងៃ ដំណើរនៃចំណេះដឹងខាងផ្លូវភេទ និងការផ្សព្វផ្សាយតាមបណ្ដាញផ្សេងៗពីការរួមភេទ គឺមានជាហូរហែ។ លោកអ្នកមិនអាចគេចផុតពីការនេះឡើយ នៅពេលដែលលោក-អ្នកចេញពីផ្ទះ ឬនៅពេលដែលលោកអ្នកមើលគ្រឿងអេឡិចត្រូនិច។ ក្នុងនាមជាគ្រីស្ទបរិស័ទ យើងងាយនឹងប្រឈមមុខនឹងការចូលស្ទឹងតាមបត់ចូលទូកតាមកំពង់ និងចូលស្រុកតាមប្រទេសខ្លាំងណាស់។ យើងប្រឈមមុខនឹងការប្រឡូកចូលទៅក្នុងទម្លាប់ និងវប្បធម៌ដែលប្រែប្រួលទៅតាមសម័យកាលទំនើបនេះណាស់។ ហេតុដូច្នេះហើយបានជាខ្ញុំ និងគ្រីស្ទបរិ-ស័ទផ្សេងទៀតសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទនៅក្នុងចិត្ត និងក្នុងជី-វិតរស់នៅរបស់យើង។ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យសង្វាតឲ្យបាន

បរិសុទ្ធខាងឯផ្លូវភេទ។ សូមអរព្រះគុណដល់ព្រះ ដែលទ្រង់បានបណ្ដាលឲ្យអ្នកនិពន្ធព្រះគម្ពីរ និពន្ធនៅជំនាន់ដែលពោរពេញទៅដោយការខ្វះក្រមសីលធម៌ផ្នែកផ្លូវភេទដែរ ហើយប្រាជ្ញាដែលពួកគាត់បានចែករំលែកដល់យើង គឺអាចឲ្យយើងប្រើក្នុងសម័យណាក៏បាន។ ខគម្ពីរខាងក្រោមនេះជាខដែលមានរៀបរាប់ពីកង្វះនៃក្រមសីលធម៌ ក៏ដូចជាផ្ដល់ប្រាជ្ញាដល់យើងក្នុងការរស់នៅប្រកបដោយក្រមសីលធម៌៖

១ថែស្សាឡូនីច ៤:៣-៤ «ដ្បិតនេះជាបំណងរបស់ព្រះជាម្ចាស់ គឺឲ្យអ្នករាល់គ្នាបានបរិសុទ្ធ ដើម្បីឲ្យអ្នករាល់គ្នាចៀសវាងអំពើអសីលធម៌ខាងផ្លូវភេទ ហើយម្នាក់ៗត្រូវចេះគ្រប់គ្រងរូបកាយរបស់ខ្លួនដោយបរិសុទ្ធ និងសេចក្ដីថ្លៃថ្នូរ» (គគខ)។

១ពេត្រុស ១:១៥ «ប៉ុន្តែ ចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធខាងឯការប្រព្រឹត្តទាំងអស់ ដូចព្រះអង្គដែលបានត្រាស់ហៅអ្នករាល់គ្នា ព្រះអង្គបរិសុទ្ធ» (គគខ)។

១កូរិនថូស ៦:១២-២០ «ខ្ញុំមានសិទ្ធិធ្វើអ្វីៗទាំងអស់ ប៉ុន្តែមិនមែនអ្វីៗទាំងអស់សុទ្ធតែមានប្រយោជន៍ទេ ខ្ញុំមានសិទ្ធិធ្វើអ្វីៗទាំងអស់មែន ប៉ុន្តែខ្ញុំមិនឲ្យអ្វីមួយគ្រប់គ្រងលើខ្ញុំបានឡើយ។ អាហារសម្រាប់ក្រពះ ហើយក្រពះក៏សម្រាប់អាហារដែរ ប៉ុន្តែព្រះជាម្ចាស់នឹងបំផ្លាញរបស់ទាំងពីរនេះ រីឯរូបកាយវិញមិនមែនសម្រាប់អំពើអសីលធម៌ខាងផ្លូវភេទទេ គឺសម្រាប់ព្រះអម្ចាស់ ហើយព្រះអម្ចាស់ក៏សម្រាប់រូបកាយដែរ។ ព្រះជាម្ចាស់ដែលបានប្រោសព្រះអម្ចាស់ឲ្យរស់ឡើងវិញនឹងប្រោសយើងឲ្យរស់ឡើងវិញ ដោយសារអំណាចរបស់ព្រះអង្គដែរ តើអ្នករាល់គ្នាមិនដឹងទេឬថា រូបកាយរបស់អ្នករាល់-

គ្នាជាអវយវៈរបស់ព្រះគ្រីស្ទ? ដូច្នេះ តើគួរឲ្យខ្ញុំយកអវយវៈរបស់ព្រះគ្រីស្ទធ្វើជាអវយវៈរបស់ស្ត្រីពេស្យាបានឬ? ទេ មិនបានជាដាច់ខាត ឬមួយអ្នករាល់-គ្នាមិនដឹងថា អ្នកដែលរួមរ័កជាមួយស្ត្រីពេស្យា មានរូបកាយតែមួយជាមួយនាង ដ្បិតមានសេចក្តីចែងទុកថា៖ «អ្នកទាំងពីរនឹងត្រឡប់ជារូបកាយតែមួយ» រីឯអ្នកដែលរួមរស់ជាមួយព្រះអម្ចាស់ក៏មានវិញ្ញាណតែមួយជាមួយព្រះអង្គដែរ។ ចូររត់គេចចេញពីអំពើអសីលធម៌ខាងផ្លូវភេទ។ បាបទាំងឡាយដែលមនុស្សប្រព្រឹត្ត គឺនៅក្រៅរូបកាយទេ ប៉ុន្តែអ្នកដែលប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទ ធ្វើបាបទាស់នឹងរូបកាយរបស់ខ្លួនហើយ ឬមួយអ្នករាល់គ្នាមិនដឹងថា រូបកាយរបស់អ្នករាល់គ្នាជាព្រះវិហាររបស់ព្រះវិញ្ញាណបរិសុទ្ធដែលនៅក្នុងអ្នករាល់គ្នា គឺជាព្រះវិញ្ញាណដែលអ្នករាល់គ្នាបានទទួលពីព្រះជាម្ចាស់ ដូច្នេះ អ្នករាល់គ្នាមិនមែនជារបស់ខ្លួនឯងទៀតទេ ដ្បិតព្រះអង្គបានបង់ថ្លៃលោះអ្នករាល់គ្នារួចហើយ ដូច្នេះចូរសរសើរតម្កើងព្រះជាម្ចាស់ដោយរូបកាយរបស់អ្នករាល់គ្នាចុះ» (គគខ)។

យ៉ូហាន ៤:១៦-១៨ «ព្រះអង្គមានបន្ទូលទៅនាងថា៖ «ចូរទៅហៅប្តីរបស់អ្នកមកទីនេះ» ស្ត្រីនោះទូលទៅព្រះអង្គវិញថា៖ «ខ្ញុំគ្មានប្តីទេ»។ ព្រះយេស៊ូវមានបន្ទូលថា៖ «អ្នកនិយាយថា គ្មានប្តី នោះត្រូវហើយ ដ្បិតអ្នកមានប្តីប្រាំនាក់មកហើយ រីឯបុរសដែលនៅជាមួយអ្នកសព្វថ្ងៃនេះមិនមែនជាប្តីរបស់អ្នកទេ ដូច្នេះពាក្យដែលអ្នកនិយាយនេះ ពិតប្រាកដហើយ» (គគខ)។

សុភាសិត ជំពូក៧។ល។

ការសង្វាតឲ្យបានបរិសុទ្ធខាងផ្លូវភេទមានពីរចំណុច៖ ការងាកបែរចេញ

និងការងាក*បែរទៅរក*។ ការបញ្ឈប់ឥរិយាបថណាមួយ និងការចាប់ផ្ដើមឥរិយាបថណាមួយផ្សេងទៀត។ ជារឿយៗ ក្នុងការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ ខ្ញុំតែងតែមានបទបញ្ញាដោយហាមខ្លួនឯងបែបអវិជ្ជ-មានថា៖ កុំធ្វើនេះ! កុំមានឥរិយាបថបែបនោះ! កុំបន្តទម្លាប់នេះទៀត! ហើយខ្ញុំគិតថា ពេលខ្លះយើងក៏ជឿដែរថា ប្រសិនបើខ្ញុំគ្រាន់តែបញ្ឈប់ទម្លាប់អាក្រក់នោះ គឺខ្ញុំនឹងមានភាពស្អាតស្អំខាងឯផ្លូវភេទហើយ។ ប៉ុន្តែ ចូរចងចាំថា ភាពបរិសុទ្ធខាងឯផ្លូវភេទក៏ជាបទបញ្ញាបែបវិជ្ជមានផងដែរ។ តាមពិត ខ្ញុំគិតថាវាពិតជាបទបញ្ញាបែបវិជ្ជមានទាំងស្រុង។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ មិនមែនគ្រាន់តែជាការគេចពីអ្វីដែលអាក្រក់ឡើយ ប៉ុន្តែវាក៏ជាការសង្វាតដេញតាម ហើយទាញយកអំណរចេញពីអ្វីដែលល្អផងដែរ។

ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ មិនមែនគ្រាន់តែជាការងាកបែរចេញពីបាបប៉ុណ្ណោះឡើយ ប៉ុន្តែក៏ជាការមានចិត្តរីករាយក្នុងអំណោយទានរបស់ព្រះជាម្ចាស់ផងដែរ។ គោលបំណងចម្បង គឺមិនមែនការឈប់សង្វាតតាមអ្វីៗដែលអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការសង្វាតតាមនូវអ្វីដែលល្អ ហើយមានចិត្តរីករាយក្នុងការនោះដែរ។ ការព្យាយាមសង្វាតឲ្យបានបរិ-សុទ្ធខាងឯផ្លូវភេទ គឺជាការគេចចេញពីអំពើអសីលធម៌ខាងផ្លូវភេទ បោះបង់ចោលរឿងរ៉ាវអាក្រក់ៗ ឈប់មើលរូបអាសអាភាស និងការតាំងសញ្ញាជាមួយភ្នែកខ្លួនឯង។ ទាំងនេះជាចំណុចល្អ ហើយវាជាការចាំបាច់។ ប៉ុន្តែ ចំ-ណុចនៃការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ មានលើសពីនោះទៅទៀត ពោលគឺវាល្អជាងនោះណាស់។ វាមានលក្ខណៈវិជ្ជមានជាងនោះ។

ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ គឺជាការសង្វាតចាប់ចិត្ត គំនិត និងរាងកាយរបស់ប្រពន្ធខ្លួន។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ គឺជាការមានចិត្តរីករាយក្នុងការរួមភេទជាមួយនឹងប្ដីខ្លួន។ ការព្យា-យាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ គឺជាការចងចាំពីការរួមភេទលើកមុន ហើយជាការទន្ទឹងរង់ចាំនៅពេលអនាគត។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ គឺជាការអរសប្បាយរវាងប្ដី និងប្រពន្ធ។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ គឺជាការមើលប្រពន្ធខ្លួនឯងដោយស្រ-ឡាញ់នាង។

ឱប្ដីរាល់គ្នាអើយ! ការដែលលោកឈប់មើលរូបអាសអាភាសមិនមែនជាការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទទេ ប៉ុន្តែនៅពេលដែលអ្នកមានចិត្តរីករាយក្នុងការរួមដំណេកជាមួយនឹងប្រពន្ធខ្លួន ហើយនៅពេលដែលលោកអ្នកប្រព្រឹត្តិចំពោះរូបកាយប្រពន្ធខ្លួនដោយចិត្តបរិសុទ្ធ និងផ្ដល់កិត្តិយសដល់នាង នោះទើបជាការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ។ ឱប្រពន្ធរាល់គ្នាអើយ! ការដែលនាងគេចចេញពីសេចក្ដីល្បួងខាងឯផ្លូវភេទ ឬការរួមភេទមិនអស់ពីចិត្ត មិនមែនជាការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទទេ ប៉ុន្តែនៅពេលដែលនាងមានការរួមចំណែក ក៏ដូចជាមានចិត្តរីក-រាយក្នុងការរួមដំណេកជាមួយប្ដីរបស់នាង នោះទើបជាការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទ។

តើលោកអ្នកឃើញដែរឬទេ? ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទមិនមែនគ្រាន់តែជាការគេចចេញពីអ្វីមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការ

សង្វាត និងការមានចិត្តរីករាយទៅនឹងអ្វីផ្សេងទៀត។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទជាការសម្លាប់ទម្លាប់ចាស់ៗចោល ដើម្បីឲ្យខ្លួនមានសេរីភាពក្នុងការសង្វាតដេញតាមទម្លាប់ដ៏ល្អៗជាងនោះទៅទៀត។ ព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការរំដោះលោកអ្នកចេញពីអំពើបាប ដើម្បីឲ្យលោកអ្នកមានការរីករាយក្នុងអំណោយទានរបស់ទ្រង់។ ការព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទតាមបទបែបរបស់ព្រះជាម្ចាស់ គឺជាការសង្វាតឲ្យបានបរិសុទ្ធបែបវិជ្ជមាន។

**បណ្ដាំសម្រាប់អ្នកនៅលីវ៖** ពេលនេះ ព្រះជាម្ចាស់ក៏នៅមានព្រះហឫទ័យឲ្យអ្នកព្យាយាមសង្វាតឲ្យបានបរិសុទ្ធខាងឯផ្លូវភេទដែរ ទោះបើអ្នកមិនទាន់អាចមានភាពអរសប្បាយក្នុងការរួមភេទនៅឡើយក៏ដោយ។ បទបញ្ជាឲ្យចៀសចេញពីអំពើអសីលធម៌ខាងផ្លូវភេទ គឺជាការផ្ដល់ឲ្យលោកអ្នកមានសេរីភាព និងមានអំណរក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់ ព្រមទាំងការទទួលព្រះពរតាមរយៈការស្ដាប់បង្គាប់នោះ។ ព្រះយេស៊ូវបានដកពិសោធន៍ក្នុងសេរីភាពនេះ ដោយទ្រង់បានមានព្រះជន្មគង់នៅយ៉ាងល្អឥតខ្ចោះ ទោះបើទ្រង់មិនមានការរួមភេទក៏ដោយ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Tim Challies
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់, លោក ទេព រ៉ូ និង លោក អ៊ុន ជ័យរិទ្ធ
ដកស្រង់ខ្លះៗចេញពី http://www.challies.com/articles/positive-purity/
ដោយមានការអនុញ្ញាត។
លោកអ្នកអាចអានអត្ថបទនេះនៅលើគេហទំព័រ https://plovpit.com/positive-purity/

# ៥

# ទង្វើ៧យ៉ាង ដែលយើងគួរធ្វើ បន្ទាប់ពីមើល រូបភាពមិនគប្បី

ការប្រឹក្សាភាគច្រើនរបស់គ្រីស្ទបរិស័ទទាក់ទងនឹងការញៀនមើលរូបភាព ឬក៏វីដេអូអាសអាភាស មិនសូវជាមានប្រយោជន៍ប៉ុន្មានទេ។ ត្រង់ចំណុចនេះ ខ្ញុំចង់មានន័យថា៖ ការប្រឹក្សាទាំងនោះមិនបានជួយបង្កើតឲ្យមានការប្រែចិត្តពិតប្រាកដ ការព្យាបាលឲ្យជាសះស្បើយ ការស្តារឡើងវិញ និងការត្រឡប់ទៅរកភាពដើមវិញទាំងស្រុងនោះទេ។ លើសពីនោះទៅទៀត ការប្រឹក្សាទាំងនេះមិនបានលើកឡើងពីមូលហេតុនៃការកុហកដ៏ចម្បងទាក់ទងនឹងការមើលរូបភាព ឬក៏វីដេអូអាសអាភាសដល់យើងនោះទេ។ សរុបមក ការប្រឹក្សាទាំងនោះមានចំណុចរួមពីរ៖ ចំណុចទីមួយគឺទាក់ទងនឹងគំនិតអំពីទេវវិទ្យា និងខគម្ពីរច្រើនពេកដែលគ្រាន់តែជាចំណេះដឹងក្នុងខួរក្បាល ហើយមិនអាច

យកមកអនុវត្តបាន។ ចំណុចទីពីរ៖ ការប្រឹក្សានោះគ្រាន់តែលើកឡើងពីច្បាប់ឲ្យទៅធ្វើនេះ ធ្វើនោះនៅតែខាងសម្បកក្រៅ ហើយច្បាប់ទាំងនោះមិនអាចជួយយើងក្នុងជីវិតរស់នៅ ពោលគឺពីភាពបរាជ័យ និងពីការតស៊ូ ដើម្បីឲ្យបានសេចក្តីសង្ឃឹម។ តើដំណឹងល្អមានប្រយោជន៍អ្វីទាក់ទងនឹងភាពបរាជ័យរបស់យើង និងការព្យាយាមជាថ្មីដែលកើតឡើងម្តងហើយម្តងទៀត?

ពេលដែលយើងជឿថា គ្មានបុគ្គលណាម្នាក់ក្នុងក្រុមជំនុំដែលកំពុងតែតយុទ្ធនឹងអំពើបាបទេ នោះយើងក៏នឹងមិនហ៊ាននិយាយពីអំពើបាបក្នុងក្រុមជំនុំ ឬក៏និយាយជាមួយបុគ្គលដែលកំពុងតែតយុទ្ធ ក៏ដូចជានិយាយមកកាន់ខ្លួនឯងនោះឡើយ។ តើវាជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយអំពីអ្វីដែលព្រះគ្រីស្ទអាចធ្វើបាន (និងអំពីអ្វីដែលយើងអាចធ្វើបាន) បន្ទាប់ពីយើងបានបណ្តោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូអាសអាភាស? ឬក៏យើងគ្រាន់តែអង្គុយធ្វើហៃៗ ដោយសង្ឃឹមថា គ្មាននរណាម្នាក់ប្រព្រឹត្តបាបនោះឡើយ? មានអ្នកខ្លះបានលើកឡើងថា «ហេតុអ្វីបានជាយើងនៅគួរគិតថាយើងស័ក្តិសមនឹងឲ្យព្រះជាម្ចាស់នឹងមកជួបយើង ទាំងខ្លួនយើងបានប្រព្រឹត្តបាបដ៏អាស្រូវដូចនេះ? តាមពិត យើងមិនគួរទាំងបណ្តោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូអាសអាភាសផង។» ប៉ុន្តែ តាមពិតទៅ មនុស្សជាច្រើនតែងតែធ្លាក់ជាប់នៅក្នុងកាលៈទេសៈបែបនោះ ហើយព្រះជាម្ចាស់អាចនឹងប្រើកាលៈទេសៈនៃភាពសោកស្តាយទាំងនោះឲ្យទៅជាប្រយោជន៍ដល់យើង។

បន្ទាប់ពីយើងបានបិទទ្វារ បិទភ្លើងនៅក្នុងបន្ទប់តែម្នាក់ឯង ហើយបានមើលរូប ឬក៏រឿងមិនគួរគប្បី ពេលនោះឯងជាពេលដែលអារក្សសាតាំងនឹងធ្វើ

គ្រប់យ៉ាង ដើម្បីឲ្យផែនការរបស់វាបានសម្រេចៈ វាគម្រាមកំហែងដល់របៀបគិតគូរបស់យើង វានាំឲ្យយើងគិតថា យើងអាចធ្វើអ្វីមួយដើម្បីឲ្យព្រះអង្គអត់-ទោសបាបយើង បាន (ដូចជាសន្យាថានឹងកាន់តែបម្រើព្រះអង្គ កាន់តែអធិ-ស្ឋាន អានព្រះគម្ពីរ តែធាតុពិត ការទាំងនេះមិនមែនជាមធ្យោបាយដែលនាំឲ្យព្រះជាម្ចាស់អត់ទោសបាបយើងទេ តែគឺជាព្រះគុណរបស់ព្រះទៅវិញទេតើ) ហើយអារក្សសាតាំងថែមទាំងមួលបង្កាច់ ដើម្បីឲ្យយើងស្អប់ខ្លួនឯងផងដែរ។ បន្ទាប់ពីយើងបានធ្លាក់ទៅក្នុងការមើលរូបភាព ឬក៏វីដេអូអាសអាភាសនោះឯងជាពេលដែលអារក្សសាតាំងព្យាយាមយ៉ាងខ្លាំងក្នុងការរារាំងយើងពីមាគ៌ារបស់ព្រះជាម្ចាស់។  ខាងក្រោមនេះគឺជាចំណុចដ៏ជាក់លាក់មួយចំនួនដែលយើងអាចប្រើប្រាស់បានក្នុងការស្វែងរកព្រះគុណ បន្ទាប់ពីយើងបានភ្លាត់ស្នៀតនៅក្នុងការបណ្តោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូមិនគួរគប្បីៈ

## ១. ត្រូវស្គាល់ខ្មាំងសត្រូវរបស់ខ្លួន

បន្ទាប់ពីលោកអ្នកបានបណ្តោយខ្លួនឲ្យទៅមើលរូបភាព ឬក៏រឿងអាស-អាភាសហើយ នោះមានការពីរយ៉ាងដែលលោកអ្នកទំនងនឹងធ្វើៈ ទីមួយ ស្អប់ខ្លួនឯង ឬក៏ ទីពីរ គេចចេញពីខ្លួនឯង។ ទោះបីជាលោកអ្នកជ្រើសរើសដើរផ្លូវមួយណាក៏ដោយ ក៏អារក្សសាតាំងនៅតែសប្បាយចិត្តដែរ។ ជម្រើសនៃគន្លងទាំងពីរនោះ គឺជាការជឿលើការចោទប្រកាន់របស់អារក្សសាតាំង (ម៉ាថាយ ១៦:២៣; ២កូរិនថូស ៧:១០)។ ចូរទទួលស្គាល់ថា លោកអ្នកមានខ្មាំងសត្រូវផ្ទាល់ខ្លួនដ៏ពូកែ ហើយការងារជាចម្បងរបស់វា គឺបំផ្លាញលោក-

អ្នកចោល (យ៉ូប ១:៧; អេភេសូរ ២:២; យូដាស ១:១៩)។ ចូរទទួលស្គាល់ ហើយដឹងថា អារក្សសាតាំងកំពុងតែធ្វើការទាក់ទងនឹងរាល់បទពិសោធន៍ ដែលលោកអ្នកមាន ឧទាហរណ៍៖ គំនិតគិត សម្ពប់ ការប្រឡូកប្រឡាក់ អារម្មណ៍ ផែនការ។ល។ ប្រសិនបើលោកអ្នកងាយនឹងភ្លេចពីការនេះ នោះ លោកអ្នកនឹងងាយក្នុងការទទួលជឿលើសេចក្ដីកុហកដ៏ពោរពេញដោយការ បំផ្លាញ ការលាក់បាំង ការផ្ដួលរំលំ និងល្បិចកិច្ចកល។ នៅពេលដែលព្រះ យេស៊ូវមានបន្ទូលប្រាប់ពួកផារិស៊ីថា អារក្សសាតាំងដែលជាមេកុហកគឺជា ឪពុករបស់ពួកគេ វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលពួកគេ មិនដឹងអំពីការនោះ។ អារក្សសាតាំងមិនចង់ឲ្យពួកគេដឹងថា វាជាឪពុករបស់ ពួកគេទេ ព្រោះអំពើអាក្រក់នឹងកាន់តែកើនឡើង នៅពេលដែលយើងភ្លេចវា (យ៉ូហាន ៨:៤៤)។ ចូរកុំភ្លេច៖ ក្រោយពេលដែលលោកអ្នកបណ្ដោយខ្លួន ឲ្យទៅមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺការតយុទ្ធទើបតែដល់ពាក់ កណ្ដាលទីប៉ុណ្ណោះ ហើយបុគ្គលដែលលោកអ្នកកំពុងតយុទ្ធជាមួយនោះ គឺជាបុគ្គលដ៏អាក្រក់ ដែលមិនងាយបោះបង់ការព្យាយាមបំផ្លាញជីវិតរបស់ លោកអ្នកចោលនោះឡើយ ប៉ុន្តែវាមិនទាន់យកជីវិតរបស់លោកអ្នកបាន នៅឡើយទេ។

## ២. ព្យាយាមកុំស្អប់ខ្លួនឯង

យើងមិនចាំបាច់សួរដើម្បីឲ្យដឹងថា៖ ការមើលរូបភាព ឬក៏វីដេអូអាស-អាភាសគឺជាការបញ្ចុះបញ្ចូលដ៏អាក្រក់ដើម្បីឲ្យយើងជឿថា ការត្រេកត្រអាល

ចង់បានអ្វីមួយដែលប្លែក គឺជារឿងគ្មានទោសនោះទេ។ ការមានសតិបញ្ញាដែលឈឺចាប់ គឺជាចំណុចដ៏ល្អមួយ។ ប៉ុន្តែ នៅពេលដែលលោកយូដាសដឹងខ្លួនថា «ខ្ញុំបានធ្វើបាប ព្រោះខ្ញុំបានបានក្បត់នឹងឈាមដែលឥតទោស» គឺវាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលគាត់ «ចេញទៅក្រៅ រួចចងកសម្លាប់ខ្លួន» (ម៉ាថាយ ២៧:៤-៥ គកស)។ នេះគឺជាអារម្មណ៍ធម្មតាទេ ដែលយើងចង់ដាក់ទោសខ្លួនឯងនៅពេលដែលយើងក្បត់នឹងមនុស្សដែលឥតទោស។ តាមរយៈការដែលយើងមួលបង្កាច់មនុស្សដែលគ្មានទោស នោះយើងក៏ដាក់ទោសខ្លួនឯងដែរ។ ហេតុដូច្នេះហើយបានជាមានមនុស្សជាច្រើនសម្លាប់ខ្លួនដោយសារការមើលរូបភាព ឬក៏វីដេអូមិនត្រឹមត្រូវ។ មនុស្សមួយចំ-នួនទំនងជាគិតថា «ខ្ញុំមិនល្អដូចជាអ្វីដែលគ្រូគង្វាល ឬក៏អ្នកនិពន្ធមួយចំនួនចង់ឲ្យខ្ញុំល្អនោះទេ»។ នៅទីបំផុត ការបង្ខូចភាពថ្លៃថ្នូររបស់មនុស្សនឹងកាន់តែបង្ខូចអស់អ្នកដែលមើលរូបភាព និងវីដេអូអាសអាភាស ហើយក៏នឹងនាំពួកគាត់ឲ្យកាន់តែស្អប់ខ្លួនឯង ក៏ដូចជានាំពួកគាត់ឲ្យខ្ពើមរអើមខ្លួនឯងដែរ។ យើងស្អប់ យើងរិះគន់ យើងឆ្អើម ហើយយើងខ្ពើមខ្លួនឯងយ៉ាងខ្លាំង! ភាពសោកសង្រេងចំពោះការទាស់នឹងខ្លួនឯង ហើយមានអារម្មណ៍ថា យើងត្រូវតបស្នងទៅកាន់ព្រះជាម្ចាស់វិញ ចំពោះអំពើបាបដែលយើងបានប្រព្រឹត្តិ គឺជារឿងខូចចិត្តយ៉ាងខ្លាំង ហើយក៏ជាការធ្វើទារុណកម្មខ្លួនឯងដ៏ព្រៃផ្សៃបំផុតដែរ។

ហេតុដូច្នេះហើយបានជាស្តេច ដាវីឌ ប្រើការប្រៀបធៀបដ៏ស៊ីជម្រៅអំពីសាច់ឈាម នៅពេលដែលទ្រង់ទូលអង្វរសូមព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការលុបអំពើបាបខាងផ្លូវភេទរបស់គាត់៖ «សូមលុបអំពើរំលងរបស់

ទូលបង្គំចេញ» «សូមលាងទូលបង្គំ» «សូមសម្អាតទូលបង្គំ» «ទូលបង្គំមានបាបតាំងពីនៅក្នុងផ្ទៃម្តាយ» «សូមជម្រះទូលបង្គំ» «សូមលាងសម្អាតទូលបង្គំ (ម្តងទៀត)» «សូម...លុបបំបាត់អំពើទុច្ចរិតទាំងប៉ុន្មានរបស់ទូលបង្គំ» «សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ» (ទំនុកដំកើង ៥១:១, ២, ៥, ៧, ៩, ១០)។ នេះជាការស្រែកអង្វរដ៏សាមញ្ញ៖ «បាបនោះនៅក្នុងទូលបង្គំ! សូមដកវាចេញទៅ!» «សូមបញ្ឈប់ទូលបង្គំ!» «ទូលបង្គំស្អប់វាណាស់!» «ទូលបង្គំស្អប់ខ្លួនឯងណាស់!» «សូមលាងទូលបង្គំនឹងទឹកអូសាវែល។» ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលទ្រង់ដល់យើង ដែលមានទាំងការឈឺចាប់ និងសេចក្តីសង្ឃឹមក្នុងជំពូកតែមួយ។ ចូរតយុទ្ធដូចដែលស្តេច ដាវីឌ បានធ្វើ។ ចូរស្រែកយំដូចដែលស្តេច ដាវីឌ បានយំ។ ចូរដូរសម្រែកថ្ងូចថ្ងូរនៃការស្អប់ខ្លួនឯងជាមួយនឹងក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលគ្មានលក្ខខណ្ឌ។

ប្រសិនបើលោកអ្នកត្រូវល្បួងឲ្យលិចលង់នៅក្នុងការឈឺចាប់តែម្នាក់ឯង ចូរកុំអនុញ្ញាតឲ្យការស្អប់ខ្ពើមអំពើបាបនោះ នាំឲ្យលោកអ្នកស្អប់ខ្លួនឯងឡើយ។ ចូរមានការអត់ធ្មត់ចំពោះខ្លួនឯង ដ្បិតព្រះជាម្ចាស់ទ្រង់អត់ធ្មត់។ ព្រះអង្គកំពុងតយុទ្ធ ដើម្បីជីវិតរបស់លោកអ្នក (លោកុប្បត្តិ ៣២:២៤; យ៉ូហាន ១០:១០)។ ព្រះអង្គមិនភ្លេចលោកអ្នកទេ ហើយព្រះអង្គក៏មិនបានចាកចេញពីលោកអ្នកដែរ។ ចូរបន្តជាមួយទ្រង់នៅក្នុងការតយុទ្ធ។ ចូរបន្តដេញចាប់ខ្យល់ដង្ហើមនៃជីវិតរបស់ព្រះជាម្ចាស់ ព្រោះទ្រង់ជាវិញ្ញាណដែលប្រទានជីវិត (១កូរិនថូស ១៥:៤៥)។

## ៣. តយុទ្ធនឹងការយល់ឃើញមិនច្បាស់លាស់

ក្រោយពេលដែលយើងបានបណ្តោយខ្លួនឲ្យទៅមើលរូបភាព ឬក៏វីដេអូអាសអាភាសហើយ នោះយើងនឹងមានភាពស្រពិចស្រពិលនៅក្នុងការយល់ឃើញរបស់យើង។ ព្រះយេស៊ូវបានជ្រាបពីការនេះ «មានពរហើយ អស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ» (ម៉ាថាយ ៥:៨)។ ភាពបរិសុទ្ធ គឺជាការទទួលយកគុណធម៌ដ៏ត្រចះត្រចង់។ ចុះភាពមិនបរិសុទ្ធវិញ? វាគឺជាការដែលធ្វើឲ្យយើងកាន់តែជក់ចិត្តក្នុងការលួចលាក់ធ្វើបាបម្នាក់ឯង និងជាការគេចចេញពីព្រះជាម្ចាស់ ពីអ្នកដទៃ និងពីខ្លួនឯង និងវាធ្វើឲ្យយើងមានភាពស្ពឹកស្រពន់ វង្វេងស្មារតី ស្លាប់ និងលែងដឹងខុសត្រូវ។ អំពើបាបខាងផ្លូវភេទតែងតែកាត់បន្ថយការយល់ឃើញខាងឯព្រលឹងវិញ្ញាណ។ ជាថ្មីម្តងទៀត នេះគឺជាអារម្មណ៍ដែលមនុស្សគ្រប់គ្នាធ្លាប់មាន៖ ការលុបចោលនូវអ្វីៗដែលលោកអ្នកបានមើលនៅលើប្រព័ន្ធអ៊ីនធឺណិត ការខំប្រឹងធ្វើនេះធ្វើនោះដោយមិនអស់ចិត្ត ហើយម្តងទៅធ្វើការនេះ ម្តងទៅធ្វើការនោះ ម្តងទៅនិយាយជាមួយអ្នកនេះ ម្តងទៅនិយាយជាមួយអ្នកនោះ គឺយើងស្ទើរតែមានអារម្មណ៍ថា ជីវិតយើងគ្មានន័យអ្វីទាំងអស់ ហើយស្ទើរតែថាខ្លួនឯងលែងជាមនុស្សទៀតផង ពោលគឺគ្មានការឆេះឆួលសល់ទៀតទេ។ យើងមានអារម្មណ៍បែបនោះ ព្រោះធាតុពិតនៃការបណ្តោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូអាស-អាភាសបានបង្កប់ដោយការមានអារម្មណ៍បែបនោះ។

និយាយឲ្យចំទៅ ការមានអារម្មណ៍បែបនោះ គឺគ្មានអ្វីដែលយើងអាចធ្វើបាននោះទេ លើកលែងតែបន្តរស់នៅក្នុងភាពស្មុគស្មាញ និងការវង្វេងស្មារតីរហូត

ដល់វារសាយបាត់ទៅ។ ចូរបន្តអធិស្ឋាន (អេភេសូរ ៦:១៨)។ ចូរបន្តព្យាយាមដកដង្ហើម។ ចូរប្រុងស្មារតីជានិច្ច។ ខណៈពេលដែលយើងកំពុងជាប់នៅក្នុងអារម្មណ៍នៃការបណ្តោយខ្លួនទៅមើលរូបភាព ឬរឿងមិនគប្បី គឺយើងត្រូវតែពឹងលើព្រះគុណដែលព្រះជាម្ចាស់បានប្រទានដល់យើងជារៀងរាល់ថ្ងៃ (បរិទេវ ៣:២២-២៤)។ នៅត្រង់ចំណុចនេះ យើងឃើញថា អ្នកយំសោកកំពុងតែព្យាយាម ហើយគាត់អធិស្ឋានពីអ្វីដែលគាត់មិនអាចធ្វើបាន។ «ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះ ខ្ញុំនឹងសង្ឃឹមដល់ព្រះអង្គ» (បរិទេវ ៣:២៤ គកស)។ តើពិតមែនឬ? តើលោកអ្នកនឹងសង្ឃឹមលើទ្រង់ឬទេ? ការអធិស្ឋានគឺជាការបង្ហាញពីសេចក្តីសង្ឃឹម។ សេចក្តីអធិស្ឋានមួយនេះ គឺជាចំណែករបស់អ្នកយំសោក ចំពោះព័ន្ធកិច្ចរបស់ព្រះជាម្ចាស់។ ចូរបន្តឈានទៅមុខ! ចូរបន្តដកដង្ហើម! ប្រសិនបើលោកអ្នកឈប់បន្តបណ្តោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូអាសអាភាស មិនយូរមិនឆាប់ លោកអ្នកនឹងលែងមានភាពស្រពិចស្រពិលនៅក្នុងការយល់ឃើញតទៅទៀតជាមិនខាន។

## ៤. ការពារអ្នកដទៃ

ការមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺជាការបង្ហាត់បង្រៀនខ្លួនឯងឲ្យចេះប្រើអ្នកដទៃ ដើម្បីបំពេញការត្រេកត្រអាលរបស់ខ្លួន។ ចូរដឹងថា ចាប់ពីពេលដែលលោកអ្នកបានមើលរូបភាព ឬក៏រឿងមិនគួរគប្បីមក នោះ លោក-អ្នកនឹងងាយធ្លាក់ទៅក្នុងការប្រើប្រាស់មនុស្ស ដែលនៅជិតលោកអ្នកតាមរបៀបមួយដូចដែលលោកអ្នកប្រើរូបភាព ឬក៏វីដេអូអាសអាភាស ដើម្បីបំពេញ

សេចក្តីអរសប្បាយរបស់ខ្លួនយ៉ាងនោះដែរ។ ពោលគឺ ដោយភាពអាត្មានិយម ដោយឥរិយាបថដែលព្រងើយកន្តើយ និងការមិនកែប្រែចិត្ត។ ការមើលរូប-ភាព ឬក៏វីដេអូអាសអាភាស ធ្វើឲ្យយើងខ្វាក់ភ្នែកនៅក្នុងទំនាក់ទំនងរបស់យើងជាមួយមិត្តភក្តិ ហើយវារារាំងយើងមិនឲ្យស្រឡាញ់អ្នកដទៃឡើយ។ ដូច្នេះ វិធីដ៏ល្អបំផុតគឺយើងត្រូវដើរដោយចេះការពារខ្លួន៖ ដើរមួយៗដោយទទួលស្គាល់ថា ខ្លួនកំពុងឈឺ ហើយងាយនឹងធ្វើបាបអ្នកដទៃដោយយកគេមកប្រើប្រាស់ទុកដូចជារបស់ប្រើប្រាស់ ពោលគឺចាត់ទុកគេអន់ជាងសត្វទៅទៀត។ ក្រោយពេលដែលលោកអ្នកធ្លាក់ចុះ វាជាការចាំបាច់ណាស់ដែលលោកអ្នកត្រូវទទួលស្គាល់ថា មនុស្សដែលនៅជុំវិញខ្លួនលោកអ្នក (មិនមែននៅលើអេក្រង់គ្រឿងអេឡិចត្រូនិករបស់លោកអ្នកទេ) ស័ក្តិសមនឹងទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរដែលលោកអ្នកមិនបានផ្តល់ឲ្យដល់អស់អ្នកដែលនៅលើអេក្រង់ដែលលោកអ្នកទើបនឹងមើល។

ការមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺប្រៀបដូចជាមើលខ្សែភាពយន្តមួយរឿង ដែលមានតួឯក មានពាក្យសម្តីដែលគេរៀបចំឲ្យនិយាយ ហើយក៏មានការសម្តែងផងដែរ៖ មានបុគ្គលដែលទទួលបានសេចក្តីអរសប្បាយ មានបុគ្គលដែលជាអ្នកផ្តល់សេចក្តីអរសប្បាយឲ្យគេ មានបុគ្គលដែលជាអ្នកលះ-បង់ និងមានបុគ្គលដែលជាអ្នកទទួលបានការលះបង់ពីអ្នកដទៃ មានបុគ្គលដែលធ្វើខ្លួនអន់ជាងសត្វ និងបុគ្គលដែលតាំងខ្លួនជាព្រះ ជាអ្នកដែលរកតែប្រយោជន៍ខ្លួនឯង។ យើងត្រូវចេះគ្រប់គ្រងខ្លួនឯង ដើម្បីឲ្យចាំថា ការមើលរូបភាព ឬក៏វីដេអូអាសអាភាស គឺជាខ្សែភាពយន្តដែលពោរពេញទៅដោយ

ការកុហក ហើយប្រសិនបើយើងចង់តយុទ្ធជាមួយការកុហកនេះ គឺយើងមិនត្រូវគិតអំពីខ្លួនឯងច្រើនពេកនោះទេ តែត្រូវគិតពីអ្នកដទៃវិញ៖ យើងត្រូវចាំពីសេចក្ដីថ្លៃថ្នូររបស់អ្នកដទៃ និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សដែលនៅជុំវិញយើង ពោលគឺមិនត្រូវតាំងខ្លួនជាព្រះ ដែលគិតតែពីប្រយោជន៍ខ្លួនឯងនោះឡើយ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងជីវិតរបស់យើង ដើម្បីកុំឲ្យសាច់ឈាមយើងត្រួតត្រាលើយើង (កាឡាទី ៥:១៧)។ ព្រះជាម្ចាស់ដ៏ជាអង្គដែលថែរក្សាយើង ទ្រង់ការពារអ្នកដទៃកុំឲ្យទទួលផលអាក្រក់ពីយើង នៅពេលដែលយើងគិតថា ខ្លួនជាព្រះ។

## ៥. សារភាពទៅកាន់មិត្តភក្តិ

ចូរសារភាពបាបរបស់លោកអ្នកទៅកាន់មិត្តភក្ដិណាម្នាក់របស់លោកអ្នក ដែលនឹងមិនរកលេសដោះសារឲ្យលោកអ្នក ហើយក៏នឹងមិនស្ដីបន្ទោសលោកអ្នកធ្ងន់ធ្ងរដែរ ព្រោះចំណុចទាំងពីរនេះសំខាន់ដូចគ្នា។ ពេលខ្លះ នៅពេលដែលយើងរកមនុស្សមកជួយយើង (ក្រោយពេលដែលយើងបានធ្លាក់ទៅក្នុងការបណ្ដោយខ្លួនទៅមើលរូបភាព ឬក៏វីដេអូអាសអាភាស) អ្នកដែលយើងចង់ឲ្យជួយ បែរជាមកជាន់ពន្លិចយើងថែមទៀតទៅវិញ (សុភាសិត ២៤:១៦)។ ចូររកមិត្តភក្តិដែលនឹងជួយផ្ដល់សេចក្ដីសង្ឃឹមដល់យើង ជួយព្យាបាលយើងនៅពេលដែលគាត់ឮការសារភាពបាបរបស់យើង។ ចំណុចស្នូលនៃការសារភាពគឺ "ដើម្បីឲ្យអ្នករាល់គ្នាបានជាសះស្បើយ" "ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមកផង" (យ៉ាកុប ១:១៦ គកស)។ ពិតណាស់ តម្លៃ

នៃ «ពាក្យអធិស្ឋានរបស់មនុស្សសុចរិត នោះពូកែ ហើយមានប្រសិទ្ធភាពណាស់» (យ៉ាកុប ៥:១៦ គកស)។ ជាការល្អណាស់ប្រសិនបើលោកអ្នកសារភាពបាបនេះទៅកាន់មនុស្សដែលមានភេទដូចគ្នា។ ការសារភាពបែបនេះ មិនមែនជារនាំងខណ្ឌផ្ដាច់មនុស្សដែលប្រព្រឹត្តិបាបពីព្រះគ្រីស្ទនោះទេ ប៉ុន្តែវាជាវិធីមួយក្នុងការព្យាបាលការឈឺចាប់។ មនុស្សមានបាបដែលមានប្រាជ្ញាប្រាកដជាសារភាពបាបរបស់ខ្លួនទៅកាន់មិត្តភក្តិដែលនឹងមិន «សង្កត់សង្កិនមនុស្សវេទនានៅត្រង់ទ្វារក្រុង» ហើយក៏នឹងមិន «រាប់សេចក្តីអាក្រក់ថាជាល្អ» (សុភាសិត ២២:២២; អេសាយ ៥:២០)។ ប្រសិនបើនៅកន្លែងដែលលោកអ្នករស់នៅមានការប្រជុំគ្នា ដើម្បីជួយដោះស្រាយបញ្ហាបែបនេះ ខ្ញុំសូមលើកទឹកចិត្តលោកអ្នកឲ្យទៅចូលរួមជាមួយគេដែរ ឧទាហរណ៍ៈ ក្រុមតូចដែលក្រុមជំនុំលោកអ្នកមាន។

## ៦. ប្រើការយល់ឃើញដ៏ច្បាស់លាស់របស់លោកអ្នក ដើម្បីជាប្រយោជន៍

ប្រាកដណាស់ លោកអ្នកនឹងមានភាពស្រពិចស្រពិលក្នុងការយល់ឃើញក្រោយពេលដែលបានធ្លាក់ទៅក្នុងការមើលរូបភាព ឬក៏វីដេអូអាសអាភាស។ ប៉ុន្តែ លោកអ្នកក៏អាចនឹងមានការយល់ឃើញយ៉ាងច្បាស់លាស់ដែរ ព្រោះនោះជាលក្ខណៈមួយនៃការក្រឡេកមើលក្រោយដោយមានការសោកស្តាយ។ «កាលយូដាស...ឃើញថាព្រះអង្គជាប់ទោស គាត់សោកស្តាយជាខ្លាំង» (ម៉ាថាយ ២៧:៣ គកស)។ ការយល់ឃើញដ៏ច្បាស់របស់លោក យូដាស

បាននាំគាត់ទៅកាន់ផ្លូវខុស។ ប៉ុន្តែ លោកអ្នកអាចប្រើការយល់ឃើញដ៏ច្បាស់របស់លោកអ្នក ដើម្បីចូលទៅកាន់ផ្លូវត្រឹមត្រូវវិញ។ ដូចគ្នាដែរសាវ័ក ប៉ុល ក៏បានសរសេរអំពីការបះបោររបស់សាសន៍អ៊ីស្រាអែលថា «ហេតុការណ៍ទាំងនោះបានកើតឡើងជាគំរូដល់យើង ដើម្បីកុំឲ្យយើងប្រាថ្នាចង់បានសេចក្តីអាក្រក់ដូចជាពួកលោក (ឡើយ)។» (១កូរិនថូស ១០:៦ គកស)។ បើនិយាយឲ្យខ្លីទៅ ពេលខ្លះយើងប្រាថ្នាចង់បានសេចក្តីអាក្រក់។ ហើយនៅក្នុងករណីនោះ គឺយើងជាគំរូដល់អ្នកដទៃហើយ។

ប្រសិនបើលោកគ្រូ ចន ផាយភ័រ (John Piper) មកនិយាយជាមួយនឹងអ្នក គាត់ទំនងជាលើកឡើងថា «កុំឲ្យការសោកស្តាយរបស់យើងក្លាយជាការឥតប្រយោជន៍នោះឡើយ»។ ចូរប្រើវាសម្រាប់សិរីល្អរបស់ព្រះជាម្ចាស់ និងសម្រាប់អំណររបស់លោកអ្នក។ ចូររៀនដាក់រនាំងទប់ស្កាត់ខ្លួនឯង។ ចូរប្រើការយល់ឃើញដ៏ច្បាស់លាស់នោះ (មុនវារសាយបាត់ទៅ) មុនពេលដែលលោកអ្នកប្រឈមមុខនឹងសេចក្តីល្បួងនោះម្តងទៀត ដើម្បីនឹងរៀបចំរនាំងទប់ស្កាត់ខ្លួនឯង។ ប្រសិនបើលោកអ្នកគ្រាន់តែអង្គុយគិតថា រនាំងនេះ ឬក៏រនាំងនោះល្អ ឬមិនល្អ ឬក៏ថាវាមាន ឬមិនមានប្រសិទ្ធភាព ប៉ុណ្ណេះ ឬប៉ុណ្ណោះ នោះចូរចាំថា មូលដ្ឋាននៃសេចក្តីពិតគឺៈ ប្រសិនបើលោកអ្នកមិនមានរនាំងទប់ស្កាត់ខ្លួនឯងពីការមើលរូបភាព ឬក៏វីដេអូអាសអាភាសនៅពេលអនាគតទេ នោះលោកអ្នកប្រាកដជានឹងមើលវាម្តងទៀតជាមិនខាន។ ប្រសិនបើលោកអ្នកមិនទាន់មានរនាំងការពារនៅឡើយទេ នោះចូរកុំបន្តនៅអែអង់ដោយគិតថា យកវិធីមួយណានោះឡើយ តែត្រូវជ្រើសរើសវិធីមួយ

ភ្លាម។ ខាងក្រោមនេះគឺជាកម្មវិធីមួយចំនួនដែលលោកអ្នកអាចជ្រើសរើស យកទៅប្រើ ដើម្បីការពារខ្លួនបាន៖

- ចូរបញ្ចូលកម្មវិធី Covenant Eyes (http://www.covenanteyes.com/) ឬក៏ X3 Watch (https://x3watch.com/) ក្នុងគ្រឿងអេឡិចត្រូនិករបស់ខ្លួន។
- ចូរកុំរក្សាទុកកម្មវិធីទាំងឡាយណា ដែលលោកអ្នកអាចប្រើ ដើម្បីលេងអ៊ីនធឺណិតដែលអ្នកផ្សេងមិនអាចដឹងថាលោកអ្នកបានមើលអ្វីខ្លះ។
- ចូរលុបចោលកម្មវិធីទាំងឡាយណា ដែលលោកអ្នកអាចចូលលេងអ៊ីនធឺណិតដោយអាចកំបាំងបាន ហើយអ្នកផ្សេងមិនដឹងថាលោកអ្នកបានចូលមើលអ្វី។
- ចូរឲ្យមិត្តភក្តិណាម្នាក់របស់លោកអ្នកបិទ app store ឬក៏ play store ចោល ដើម្បីកុំឲ្យលោកអ្នកចូលទៅទាញយកកម្មវិធី ដោយខ្លួនឯងបានដូចជា Google Chrome ជាដើម តែចូរប្រើកម្មវិធី Covenant Eyes ឬក៏ X3Watch ជាការលេងអ៊ីនធឺណិតវិញ។ សម្រាប់លោកអ្នកដែលប្រើប្រព័ន្ធ iOs ប្រសិនបើចង់បិទ ចូរចូលទៅកាន់ Link នេះ៖ https://support.apple.com/en-us/HT201304 ហើយសម្រាប់លោកអ្នកដែលប្រើប្រព័ន្ធ Andriod ចូរចូលទៅកាន់ Link នេះ៖ http://www.pcadvisor.co.uk/how-to/google-android/parental-control-on-android-image-3461359/

- ចូរលុបរូបភាពអាសអាភាស ដែលលោកអ្នកធ្លាប់ទាញទុកនៅក្នុងគ្រឿងអេឡិចត្រូនិករបស់លោកអ្នកចោល។
- ចូរសារភាពប្រាប់មិត្តភក្តិលោកអ្នកពីវិធី និងរបៀបដែលលោកអ្នកតែងតែលួចប្រើក្នុងការមើលរូបភាព ឬក៏វីដេអូអាសអាភាស។ ប្រសិនបើលោកអ្នកមិនរៀបចំផែនការនោះទេ នោះមានន័យថា លោកអ្នកបានរៀបផែនការ ទៅរកភាពបរាជ័យហើយ។ ចំណុចនេះគឺជាការពិតណាស់ ជាពិសេសទាក់ទងនឹងការតយុទ្ធជាមួយការមើលរូបភាព ឬក៏វីដេអូអាសអាភាស។

## ៧. ស្គាល់ព្រះជាម្ចាស់

ចូរចងចាំចំណុចនេះ៖ ព្រះជាម្ចាស់ស្រឡាញ់លោកអ្នកខ្លាំងណាស់! ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យចំពោះអំពើបាបដែលយើងធ្វើទេ (លោកុប្បត្តិ ៦:៦) ហើយទ្រង់ក៏ឈឺព្រះហឫទ័យនឹងយើងដែរ ប៉ុន្តែអំណាចរបស់ព្រះអង្គគឺសម្រាប់ជាប្រយោជន៍ដល់យើង (ទំនុកដំកើង ៣៤:១៧-១៩)។ ជាការពិតណាស់ ការដែលយើងមានភាពស្រពិចស្រពិលនៅក្នុងការយល់ឃើញអាចនឹងខណ្ឌផ្តាច់យើងចេញពីព្រះជាម្ចាស់បាន៖ «មនុស្សកំរោលមិនដឹងអ្វីទេ ហើយមនុស្សឆោតល្ងង់ក៏មិនយល់សេចក្តីនេះដែរ» (ទំនុកដំកើង ៩២:៦ គកស)។ ប៉ុន្តែ ទោះជាពេលដែលយើងមិនអាចមើលទ្រង់ឃើញ ហើយទោះបីជាពេលដែលយើងបរាជ័យនៅក្នុងការស្តាប់បង្គាប់ទ្រង់ក៏ដោយ ក៏យើងនៅតែអាចអធិស្ឋានបែបនេះបានដែរថា៖ ឱព្រះជាម្ចាស់អើយ! សូមរំលាយផែនការ

របស់យើងខ្ញុំ ដើម្បីកុំឲ្យយើងមិនស្តាប់បង្គាប់ទ្រង់ (នេហេមា ៤:១៥) ហើយក៏គ្មានអ្នកណាអាចឃាត់ព្រះតម្រិះរបស់ព្រះអង្គបានឡើយ (យ៉ូប ៤២:២)។ លើសពីនោះទៅទៀត ឱព្រះជាម្ចាស់អើយ! សូមជួយយើងខ្ញុំក្នុងការផ្ទេរគ្រប់ទាំងទុក្ខព្រួយរបស់យើងខ្ញុំទៅលើទ្រង់ ព្រោះទ្រង់យកព្រះហឫទ័យទុកដាក់នឹងយើងខ្ញុំ (១ពេត្រុស ៥:៦-៧)។

ព្រះជាម្ចាស់មិនបោះបង់មនុស្សមានបាបចោលឡើយ។ ព្រះអង្គក៏មិនដើរចេញពីអស់អ្នកដែលបណ្តោយខ្លួនឲ្យទៅមើលរូបភាព ឬក៏វីដេអូអាសអាភាសដែរ។ ចូររង់ចាំនៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់។ «ចូរស្អាងខ្លួននៅក្នុង...ព្រះវិញ្ញាណបរិសុទ្ធ៖ ចូររក្សាជំនឿនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះ ទាំងទន្ទឹងរង់ចាំព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ដែលនាំទៅរកជីវិតអស់កល្បជានិច្ចផង» (យូដាស ១:២០-២១)។ ចូរស្គាល់ចំណុចខុសគ្នារវាងព្រះជាម្ចាស់ និងការដែលអារក្សសាតាំងបន្លំខ្លួនធ្វើដូចជាព្រះជាម្ចាស់ ដើម្បីនឹងបោកបញ្ឆោតលោកអ្នក៖ ភាពស្អប់ខ្ពើម ការដើរចេញ ការគ្មានពេលវេលា និងការមិនចាប់អារម្មណ៍។ ចូរស្គាល់ព្រះភក្ត្រដ៏ពិតរបស់ព្រះជាម្ចាស់៖ មានពេញដោយសេចក្តីស្រឡាញ់ ការអត់ធ្មត់ ព្រមទាំងធ្វើការនៅក្នុងលោកអ្នក គ្មានអ្វីមួយធ្វើឲ្យទ្រង់ភ្ញាក់ផ្អើល គ្មានការបន្ទន់ចិត្ត ក៏គ្មានការរាថយនៅក្នុងការឈោងចាប់លោកអ្នកផងដែរ។ ព្រះអង្គនឹងមិនបោះបង់លោកអ្នកចោលឡើយ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ  Paul Maxwell
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក អ៊ុន ជ័យរិទ្ធ, លោក ជួប ប៊ុនហាក់ និង លោក ទេព រ៉ូ
ដកស្រង់ខ្លះៗចេញពី http://www.desiringgod.org/articles/seven-things-to-do-after-you-look-at-pornography ដោយមានការអនុញ្ញាត។
លោកអ្នកអាចអានអត្ថបទនេះនៅលើគេហទំព័រ https://plovpit.com/what-to-do-after-look-at-porn/

# អានបន្ថែមនៅ៖

ផ្លូវពិត

plovpit.com

## ហើយទាញយកសៀវភៅជា
## ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com